ក្រសួងអប់រំ យុវជន និងកីឡា

២០០៩ - ២០១៣

# ផែនការគោល បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំ



# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីចម្បងក្នុងការត្រៀមលក្ខណៈឲ្យសិស្សានុសិស្សមានសមត្ថភាពអាចទទួលរ៉ាប់រងការងារនៅក្នុងសង្គមប្រកបដោយជោគជ័យ។ ប្រការនេះត្រូវធានាថា ប្រទេសជាតិមានធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ ដើម្បីអភិវឌ្ឍ និងធ្វើទំនើបកម្មសេដ្ឋកិច្ច ស្របតាមយុទ្ធសាស្ត្ររួមរបស់រាជរដ្ឋាភិបាលកម្ពុជា។

ចំពោះគោលបំណងទី ១ ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាមានគោលដៅធានាថា ពលរដ្ឋកម្ពុជាគ្រប់រូបអាចទទួលបាននូវការអប់រំប្រកបដោយគុណភាព។ ចំពោះគោលបំណងទី ២ ក្រសួងត្រូវធានាថា សិស្សានុសិស្សដែលបានបញ្ចប់ការសិក្សានឹងមានសមត្ថភាពចូលក្នុងទីផ្សារការងារ។

សង្គម និងទីផ្សារការងារដែលសិស្សានុសិស្សនឹងត្រូវធ្វើសមាហរណកម្ម មានការប្រែប្រួលគួរឲ្យកត់សម្គាល់ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដែលរួមមានចាប់ពីទូរស័ព្ទរហូតដល់កុំព្យូទ័រ បានជ្រៀតចូលក្នុងជីវភាពផ្ទាល់ខ្លួន និងវិជ្ជាជីវៈ ឆ្ពោះទៅមុខយ៉ាងលឿន ដោយបានប្រែក្លាយកម្ពុជាទៅជាប្រទេសមួយដែលមានសេដ្ឋកិច្ចផ្អែកលើចំណេះដឹង។ ប្រព័ន្ធអប់រំមិនអាចស្ថិតនៅពីក្រោយការវិវឌ្ឍទាំងនេះបានឡើយ បើមិនដូច្នេះទេ សិស្សានុសិស្សនឹងប្រឈមក្នុងការទទួលបានជំនាញដែលហួសសម័យសម្រាប់សង្គមបច្ចុប្បន្ន។

ក្រសួងមិនត្រឹមតែធានាថាសិស្សានុសិស្សនឹងត្រូវទទួលបានជំនាញបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ប៉ុណ្ណោះទេ តែក៏ត្រូវធានាថារដ្ឋបាលសិក្សា និងដំណើរការបង្ហាត់បង្រៀន ក៏មានរួមបញ្ចូលនូវបច្ចេកវិទ្យាដែលសមស្រប និងមានប្រសិទ្ធភាពខ្ពស់។

ផែនការគោលស្តីពីបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ គឺជាឧបករណ៍មួយរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩ - ២០១៣ ដែលបានកំណត់ចំណុចដៅអប់រំ និងយុទ្ធសាស្ត្រដែលត្រូវសម្រេចនាពេលប៉ុន្មានឆ្នាំខាងមុខនេះ។ ផែនការនេះក៏បានកំណត់ផងដែរនូវផែនការអនុវត្តន៍ក្នុងការដាក់បញ្ចូលបច្ចេកវិទ្យាក្នុងប្រព័ន្ធអប់រំ ដើម្បីធានាថាបច្ចេកវិទ្យាត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងចីរភាព។

ផែនការគោលនេះត្រូវបានរៀបចំឡើង ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍក្នុងវិស័យអប់រំ និងបានក្លាយជាផែនការសម្របសម្រួលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា។ ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងថវិកាដល់ការរៀបចំ និងការអនុវត្តផែនការគោលនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម សិទ្ធី**

# សេចក្តីសង្ខេប

ដើម្បីអនុវត្តច្បាប់ស្តីពីការអប់រំ ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩ - ២០១៣ ស្របតាមចក្ខុវិស័យក្រសួងអប់រំ យុវជន និងកីឡា (អយក) ក្នុងការ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក និងដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន" ផែនការគោលស្តីពីបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ ២០០៩ - ២០១៣ នេះមានគោលបំណងរួមដូចតទៅ ៖

១. បង្កើនឱកាសទទួលបានការអប់រំមូលដ្ឋាន ការអប់រំថ្នាក់ឧត្តមសិក្សា និងការអប់រំពេញមួយជីវិតទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ តាមរយៈការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ធ្វើជាមធ្យោបាយបន្ថែមក្នុងការផ្តល់ការអប់រំ ។

២. បង្កើនភាពពាក់ព័ន្ធ និងប្រសិទ្ធភាពនៃការអប់រំសម្រាប់ទាំងអស់គ្នា តាមរយៈការប្រើប្រាស់សក្តានុពលនៃ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ធ្វើជាឧបករណ៍ចម្បងក្នុងការលើកកម្ពស់គុណភាពបង្រៀន និងរៀន ។

៣. អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ចាំបាច់សម្រាប់អ្នកបញ្ចប់ការសិក្សា ដើម្បីទទួលបានការងារធ្វើនៅក្នុងសង្គមដែលពឹងផ្អែកលើចំណេះដឹង និងចំណេះធ្វើ និងដើម្បីធានាថាកម្ពុជាអាចប្រកួតប្រជែង និងធ្វើសហប្រតិបត្តិការជាមួយបណ្តាញក្នុងពិភពលោក ។

៤. បង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការងារគ្រប់គ្រងក្រសួង និងសាលារៀន ។

ដោយមានការសម្របសម្រួលពីការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នាយកដ្ឋានគោលដៅមួយចំនួនរបស់ក្រសួងអប់រំ យុវជន និងកីឡានឹងទទួលខុសត្រូវសម្រេចគោលបំណងជាក់លាក់របស់ផែនការគោលដូចខាងក្រោម ៖

ចំពោះការអប់រំចំណេះទូទៅ ផែនការគោលនេះផ្តោតលើការបង្កើនការត្រៀមលក្ខណៈ និងលទ្ធភាពទទួលបានការងារធ្វើរបស់សិស្ស ដោយផ្តល់ឲ្យពួកគេនូវបំណិនវិជ្ជាជីវៈផ្អែកលើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងជំនាញត្រៀមចូលសាកលវិទ្យាល័យ ។

ចំពោះការអប់រំឧត្តមសិក្សា ផែនការគោលនេះផ្តោតលើការពង្រីកការប្រើប្រាស់កុំព្យូទ័រ បង្កើនការចូលប្រើប្រាស់ និងស្វែងរកព័ត៌មាន បង្កើនលទ្ធភាពនិស្សិតក្នុងការទទួលបានការអប់រំតាមរយៈការសិក្សាពីចម្ងាយ និងលើកកម្ពស់ការចែកចាយឯកសារសិក្សា និងស្រាវជ្រាវតាមរយៈមជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិក ។

ការបណ្តុះបណ្តាលគ្រូ នឹងត្រូវលើកកម្ពស់តាមរយៈការប្រើប្រាស់វីដេអូជាឧបករណ៍ជំនួយជាពិសេសសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ និងមុខវិជ្ជាគរុកោសល្យទូទៅ ។ គរុសិស្ស (និងគ្រូបង្រៀននៅពេលដែលអាចធ្វើបាន) នឹងទទួលបានការបង្ហាត់បង្រៀនពីរបៀបលើកកម្ពស់ការបង្រៀន

និងជំនាញរដ្ឋបាល តាមរយៈការប្រើប្រាស់កុំព្យូទ័រ និងទម្រង់ផ្សេងទៀតនៃបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ។

ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ នឹងត្រូវពង្រឹង តាមរយៈការផលិតសម្ភារសម្រាប់សិក្សាដោយខ្លួនឯង និងសម្រាប់ការសិក្សាត្រៀមកម្មវិធីថ្នាក់សមមូល និងការផលិតវីដេអូបណ្តុះបណ្តាលសម្រាប់កម្មវិធីបង្កើនប្រាក់ចំណូលរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ។

ចំពោះការគ្រប់គ្រង និងការគាំទ្រ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំ ក្រសួងនឹងធ្វើមជ្ឈការ និងរៀបចំស្តង់ដារមូលដ្ឋានទិន្នន័យ និងទម្រង់ទិន្នន័យរបស់ប្រព័ន្ធអប់រំទាំងមូល និងធ្វើវិមជ្ឈការការបញ្ចូលទិន្នន័យទៅឲ្យសាលារៀន ប្រសិនបើអាច ព្រមទាំងការិយាល័យអប់រំរាជធានី-ខេត្ត ក្រុង-ខណ្ឌ-ស្រុក ។ មន្ត្រីក្រសួងនឹងទទួលបានការបណ្តុះបណ្តាលពីការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ សម្រាប់កិច្ចការទាំងឡាយដែលកុំព្យូទ័រអាចនឹងជួយបង្កើនប្រសិទ្ធភាព និងភាពត្រឹមត្រូវក្នុងការបំពេញការងារ ។

យុទ្ធសាស្ត្ររួមក្នុងការអនុវត្តសកម្មភាពទាំងនេះ គឺចាត់ឲ្យការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ ជាអ្នកទទួលខុសត្រូវក្នុងការធានាថាការងារពាក់ព័ន្ធនឹង បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ត្រូវបានរៀបចំ សម្របសម្រួល និងអនុវត្តបានតាមការរំពឹងទុក ។

ផែនការសកម្មភាពដែលភ្ជាប់ជាមួយផែនការគោលនេះបានចែងលម្អិតពីសកម្មភាព ការសម្របសម្រួល និងការវាយតម្លៃ សម្រាប់ការអនុវត្តដោយបែងចែកជាដំណាក់កាលអនុវត្ត ទៅតាមការវាយតម្លៃបែបប្រាកដនិយមពីស្ថានភាពដែលបានបញ្ជាក់ខាងលើ ដោយគិតរួមទាំងលទ្ធភាពទទួលបានការប្រើប្រាស់ថាមពលអគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធ និងជំនាញចាំបាច់នានា ។ ផែនការសកម្មភាព ក៏បានកំណត់ពីខ្ទង់ថវិកាដែលត្រូវការដើម្បីសម្រេចឲ្យបានទាំងស្រុងនូវគោលដៅនានាផងដែរ ។

ហិរញ្ញប្បទានសម្រាប់គាំទ្រគោលដៅរយៈពេលខ្លី និងគោលដៅរយៈពេលមធ្យមភាគច្រើនត្រូវបានកំណត់រួចហើយ យើងសង្ឃឹមថា ផែនការគោលនេះនឹងជួយឲ្យដៃគូអភិវឌ្ឍបានយល់ពីការប្តេជ្ញារបស់ក្រសួងក្នុងការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដើម្បីលើកកម្ពស់ការគ្រប់គ្រង និងគុណភាពអប់រំ ដើម្បីជួយគាំទ្រផ្នែកនៅសេសសល់របស់គម្រោង។ ផែនការគោលនេះ បើកទូលាយដល់គ្រប់ដៃគូទាំងអស់ដែលមានបំណងចូលរួមអនុវត្ត និងផ្តល់នូវធនធាននានា (ហិរញ្ញវត្ថុ បច្ចេកទេស និង ធនធានមនុស្ស) ។

# ពាក្យសរសេរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AECID | Spanish Agency for International Cooperation for Development | ទីភ្នាក់ងារអេស្ប៉ាញសម្រាប់សហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍន៍ |
| AOP | Annual Operational Plan | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| CLC | Community Learning Center | មជ្ឈមណ្ឌលសិក្សាសហគមន៍ (ម.ស.ស) |
| DCD | Department of Curriculum Development | នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា (នា.អកស) |
| DF | Department of Finance | នាយកដ្ឋានហិរញ្ញវត្ថុ (នា.ហវ) |
| DHE | Department of Higher Education | នាយកដ្ឋានឧត្តមសិក្សា (នា.ឧស) |
| DGE | Directorate General of Education | អគ្គនាយកដ្ឋានអប់រំ (អគ.អរ) |
| DOE | District Office of Education | ការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុក |
| DoEYS | District Office of Education, Youth and Sport | ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង -ខណ្ឌ-ស្រុក |
| DSR | Department of Scientific Research | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ (នា.សវស) |
| ECE | Early Childhood Education | ការអប់រំកុមារតូច |
| ESP | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| EVEP | Elective Vocational Education Program | កម្មវិធីអប់រំវិជ្ជាជីវៈជម្រើស |
| EMIS | Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| FMIS | Financial Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ |
| HEI | Higher Education Institution | គ្រឹះស្ថានឧត្តមសិក្សា (គឧស) |
| HEMIS | Higher Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា |
| HRD | Department of Personnel | នាយកដ្ឋានបុគ្គលិក (នា.បល) |
| HRMIS | Human Resources Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស |
| ICT | Information Communication Technology (or Information and Communication Technologies) | បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ (បពស) |

| | | |
|---|---|---|
| ICTEO | ICT in Education Office of the Department of Information and ASEAN Affairs | ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ (ការិ.បពអ) នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន |
| InWEnt | Capacity Building International, Germany | ទីភ្នាក់ងារកសាងសមត្ថភាពអន្តរជាតិអាល្លឺម៉ង់ |
| JFIT | Japanese Funds-in-Trust | មូលនិធិជប៉ុន Fund-in-Trust |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា (អយក) |
| NFE | Non-Formal Education | ការអប់រំក្រៅប្រព័ន្ធ |
| NFED | Non-Formal Education Department | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ (នា.អកប) |
| NiDA | National Information Communication Technology Development Authority | អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (អ.អ.ប.គ.ព) |
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ (វជអ) |
| MIS | Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រង |
| ODL | Open and Distance Learning | ការសិក្សាពីចម្ងាយ និងបើកទូលាយ |
| OI | Open Institute | វិទ្យាស្ថានបើកទូលាយ (វបទ) |
| POE | Provincial Office of Education | មន្ទីរអប់រំរាជធានី-ខេត្ត |
| PoEYS | Provincial Department of Education, Youth and Sport | មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត |
| PTTC | Provincial Teacher Training College | សាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្ត (សគវ) |
| RTTC | Regional Teacher Training College | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ (មគភ) |
| TTC | Teacher Training College | សាលាគរុកោសល្យ (សគ) |
| TTD | Teacher Training Department | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (នា.បវ) |
| VPN | Virtual Private Network | បណ្តាញឯកជននិម្មិត (VPN) |
| UNESCO | United Nations Educational, Scientific and Cultural Organization | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ |

# តារាងមាតិកា

១. សេចក្តីផ្តើម.....៩
២. ស្ថានភាពបច្ចុប្បន្ន.....១០
២.១. ប្រព័ន្ធអប់រំ.....១០
២.២. ស្ថានភាពបច្ចុប្បន្នរបស់ បពស ក្នុងវិស័យអប់រំ.....១០
៣. គោលនយោបាយកំពុងអនុវត្ត.....១២
៤. គោលដៅរបស់ផែនការគោល.....១៤
៥. គោលបំណងជាក់លាក់.....១៤
៥.១. ការអប់រំចំណេះទូទៅ.....១៤
៥.២. ការអប់រំថ្នាក់ឧត្តមសិក្សា.....១៦
៥.៣. ការបណ្តុះបណ្តាលគ្រូបង្រៀន.....២០
៥.៤. ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ.....២៤
៥.៥. ការគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួង និងការគាំទ្រ បពស ក្នុងវិស័យអប់រំ.....២៦
៦. ធាតុសំខាន់ៗសម្រាប់ភាពជោគជ័យនៃការអនុវត្តផែនការគោល.....៣២
៦.១. កម្មវិធីសិក្សា.....៣២
៦.១.១. បំណិនវិជ្ជាជីវៈ បពស សម្រាប់សិស្សសាលា.....៣២
៦.១.២. អក្ខរកម្ម បពស សម្រាប់គ្រូបង្រៀន.....៣២
៦.២. សម្ភារបរិក្ខារ.....៣២
៦.២.១. សម្ភារបរិក្ខារសម្រាប់សាលារៀន និងសាលាគរុកោសល្យ.....៣២
៦.២.២. សម្ភារបរិក្ខារសម្រាប់ក្រសួង.....៣៤
៦.៣. ធនធានមនុស្ស.....៣៥
៦.៣.១. តួនាទីពាក់ព័ន្ធនឹង បពស នៅតាមសាលារៀន.....៣៥
៦.៣.២. តួនាទីពាក់ព័ន្ធនឹង បពស នៅតាមសាលាគរុកោសល្យ.....៣៥
៦.៣.៣. តួនាទីពាក់ព័ន្ធនឹង បពស នៅក្រសួង អយក និងមន្ទីរ អយក រាជធានី-ខេត្ត.....៣៦
៦.៤. ការអភិវឌ្ឍ បពស នាពេលអនាគត និងការគ្រប់គ្រងកម្មវិធី បពស.....៣៦
៦.៥. សមភាព និងសីលធម៌.....៣៧

# ១. សេចក្ដីផ្ដើម

ចក្ខុវិស័យរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា (អយក) គឺ "កសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន" ។

ស្របតាមចក្ខុវិស័យផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ក្រសួង អយក បានផ្ដួចផ្ដើមបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ (បពស) ឲ្យកាន់តែទូលំទូលាយ។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអប់រំសម្រាប់ទាំងអស់គ្នានៅគ្រប់កម្រិតសិក្សា និងដើម្បីកសាងកម្លាំងពលករប្រកបដោយសមត្ថភាពខាងបច្ចេកវិទ្យា និងសមត្ថភាពវិភាគពិចារណាជូនប្រទេសជាតិ ។

នៅឆ្នាំ ២០០៣ ក្រសួង អយក បានផ្ដើមដំណើរការកសាងគោលនយោបាយសំដៅកែលម្អគុណភាពអប់រំតាមរយៈការប្រើប្រាស់ បពស ។ នៅខែមករា ឆ្នាំ ២០០៥ ក្រសួងបានអនុម័តឲ្យប្រើប្រាស់ជាផ្លូវការឯកសារ "គោលនយោបាយ និងយុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងការអប់រំនៅកម្ពុជា" ។ ឯកសារគោលនយោបាយនេះ ត្រូវបានចាត់ទុកជាគោលនយោបាយជាតិសម្រាប់តម្រង់ទិសដៅការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ ហើយឯកសារនេះ ក៏បានកំណត់នូវសកម្មភាពចម្បងៗ ដែលក្រសួង អយក ត្រូវបំពេញ ដើម្បីឲ្យការធ្វើសមាហរណកម្មបច្ចេកវិទ្យាទាំងនេះក្នុងការរៀន និងបង្រៀននៅគ្រប់អនុវិស័យអប់រំអាចសម្រេចទៅបានដោយជោគជ័យ ។

ក្រោមជំនួយបច្ចេកទេសរបស់អង្គការយូណេស្កូ កិច្ចការកសាងឯកសារ "ផែនការគោលស្ដីពីបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ ២០០៩-២០១៣" បានចាប់ផ្ដើមនៅឆ្នាំ ២០០៧ ដែលជាផ្នែកមួយនៃកម្មវិធីសាលារៀនបើកចំហ ដែលជាកម្មវិធីកើតចេញពីកិច្ចសហប្រតិបត្តិការដ៏មានមហិច្ឆតាមួយរវាង ក្រសួង អយក និងវិទ្យាស្ថានបើកទូលាយ ។ កម្មវិធីនេះសំដៅកសាងផែនការប្រើប្រាស់ បពស នាពេលអនាគតនៅក្នុងក្រសួង អយក ដោយចាប់ផ្ដើមពីការអភិវឌ្ឍកម្មវិធីសិក្សា ការបណ្ដុះបណ្ដាលគ្រូ និងការធ្វើវិក្រឹតការគ្រូបង្រៀន ការសិក្សាវិភាគពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធ ការត្រៀមរៀបចំរចនាសម្ព័ន្ធ និងយន្តការដែលក្រសួងត្រូវការជាចាំបាច់ ការបណ្ដុះបណ្ដាលមន្ត្រីក្រសួង ការតភ្ជាប់បណ្ដាញ និងការអភិវឌ្ឍមាតិកាអប់រំសម្រាប់ការបង្រៀនទៅតាមសាលារៀន និងការបណ្ដុះបណ្ដាលគ្រូបង្រៀន ។ កម្មវិធីនេះ ក៏មានបញ្ចូលនូវការសិក្សាស្រាវជ្រាវពីបច្ចេកវិទ្យាដែលសក្ដិសមនឹងការប្រើប្រាស់នៅតាមថ្នាក់រៀននៅកម្ពុជា ដោយផ្ដោតការចាប់អារម្មណ៍ជាពិសេសទៅលើបច្ចេកវិទ្យាដែលប្រើប្រាស់ថាមពលអគ្គិសនីតិចតួច ដើម្បីឲ្យការប្រើប្រាស់មាននិរន្តរភាព ។

ផែនការគោលនេះបែងចែកការងារជាប្រាំផែនសំខាន់ៗ គឺ ៖ ការអប់រំចំណេះទូទៅ ការអប់រំឧត្តមសិក្សា ការបណ្ដុះបណ្ដាលគ្រូបង្រៀន ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ និងការគ្រប់គ្រង បពស នៅថ្នាក់ក្រសួង ។ ផែននីមួយៗសុទ្ធតែមានវត្ថុបំណងដ៏មានមហិច្ឆតា ប៉ុន្តែវត្ថុបំណងទាំងនេះអាចនឹងសម្រេចបានក្នុងរយៈពេល ៥ឆ្នាំ ។

# ២. ស្ថានភាពបច្ចុប្បន្ន

## ២.១. ប្រព័ន្ធអប់រំ

រចនាសម្ព័ន្ធនៃការអប់រំចំណេះទូទៅនៅកម្ពុជា មាន មត្តេយ្យសិក្សារយៈពេល ៣ ឆ្នាំ បឋមសិក្សារយៈពេល ៦ ឆ្នាំ (ថ្នាក់ទី ១ ដល់ថ្នាក់ទី ៦) មធ្យមសិក្សាបឋមភូមិរយៈពេល ៣ ឆ្នាំ (ថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩) និងមធ្យមសិក្សាទុតិយភូមិរយៈពេល ៣ ឆ្នាំ (ថ្នាក់ទី ១០ ដល់ថ្នាក់ទី ១២) ។

ច្បាប់ស្តីពីការអប់រំដែលបានអនុម័តនៅឆ្នាំ ២០០៧ គូសបញ្ជាក់ថា ប្រព័ន្ធអប់រំមានបញ្ចូលរបៀបសិក្សាចំនួនពីរផ្សេងទៀត ៖ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ ។ ការអប់រំពេញមួយជីវិត ត្រូវបានជំរុញនៅប្រទេសកម្ពុជា ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹង និងបំណិនដែលចាំបាច់សម្រាប់ការច្នៃប្រឌិត ផលិតភាព និងការអភិវឌ្ឍវិជ្ជាជីវៈរបស់ប្រជាពលរដ្ឋ ។

ចំពោះអ្នកដែលបានបោះបង់ចោលការសិក្សាមុនពេលបានបញ្ចប់ភូមិសិក្សាណាមួយនោះ ពួកគេនៅតែមានឱកាសចូលរៀនក្នុងកម្មវិធីអក្ខរកម្ម និងកម្មវិធីបំណិនជីវិតក្រៅប្រព័ន្ធ ដែលនឹងជួយឲ្យពួកគេអាចមានលទ្ធភាពចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្សេងៗ ដែលមានផ្តល់ជូនដោយគ្រឹះស្ថានសិក្សានានា ។

បន្ទាប់ពីបញ្ចប់ការអប់រំមូលដ្ឋានដែលមានរយៈពេល ៩ ឆ្នាំ សិស្សអាចបន្តរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឬចូលសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតមធ្យម ។ ក្រោយពេលបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ សិស្សអាចជ្រើសរើសបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ឬចូលរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ។

គ្រូបង្រៀននៅកម្ពុជា ទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ (សម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ) នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន ៦ (សម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ) នៅសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្តចំនួន ១៨ (សម្រាប់គ្រូបង្រៀនបឋមសិក្សា) និងនៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម (សម្រាប់គ្រូមត្តេយ្យ) ។ ជារៀងរាល់ឆ្នាំមានការបណ្តុះបណ្តាលគ្រូថ្មីសរុបចំនួន ៥.០០០ នាក់ បន្ថែមលើគ្រូដែលកំពុងបម្រើការងារចំនួន ៨០.០០០ នាក់ ក្នុងឆ្នាំសិក្សា ២០០៧ - ២០០៨ ។

## ២.២. ស្ថានភាពបច្ចុប្បន្នរបស់ បពស ក្នុងវិស័យអប់រំ

ដោយសារតែទម្រង់ផ្សេងៗរបស់ បពស (ដែលមានដូចជា អ៊ីនធឺណិត និងកុំព្យូទ័រ ទូរទស្សន៍ វិទ្យុ វីដេអូ និងទូរស័ព្ទចល័ត) បាននឹងកំពុងត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយ និងកាន់តែមានអន្តរកម្មនោះ តួនាទី បពស នៅគ្រប់កម្រិតសិក្សា ក៏កាន់តែមានសារៈសំខាន់ខ្លាំងឡើងក្នុងការធ្វើឲ្យលទ្ធផលសិក្សាមានការឆ្លើយតបទៅនឹងទីផ្សារពលកម្ម ការកែលម្អខ្លឹមសារអប់រំ និងការផ្ទេរចំណេះដឹង និងការបំផុស "អក្ខរកម្មព័ត៌មានវិទ្យា" ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ក្រសួងបានជំរុញការប្រើប្រាស់កុំព្យូទ័រ ដើម្បីរក្សាទិន្នន័យដែលក្រសួងត្រូវការជាចាំបាច់ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការរបស់ខ្លួន ។ ផ្នែកសំខាន់មួយចំនួនរបស់ក្រសួងត្រូវបានគ្រប់គ្រងដោយប្រព័ន្ធកុំព្យូទ័រ មានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) ប្រព័ន្ធព័ត៌មាន

គ្រប់គ្រងបុគ្គលិក (HRMIS) ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ (NFEMIS) ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) និងប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា (HEMIS)។ ប្រព័ន្ធគ្រប់គ្រងទាំងនេះ មានភាពឯករាជ្យពីគ្នា និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជំនាញនីមួយៗ ។

សាលាគរុកោសល្យ បានបញ្ចូលការបណ្តុះបណ្តាល បពស សម្រាប់គ្រូបង្រៀន ក្នុងកម្មវិធីសិក្សាចាប់តាំងពីឆ្នាំ ២០០៣ ប៉ុន្តែដោយសារតែសម្ភារបរិក្ខារមិនគ្រប់គ្រាន់ ការបណ្តុះបណ្តាល បពស អាចធ្វើទៅបានតែនៅតាមសាលាគរុកោសល្យមួយចំនួនប៉ុណ្ណោះ ។ សាលារៀនមួយចំនួនបានទទួលអំណោយជាកុំព្យូទ័រដោយផ្ទាល់ពីអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ។

ក្នុងការត្រៀមអនុវត្តផែនការគោលនេះ កម្មវិធីសាលារៀនបើកចំហដែលបានចាប់អនុវត្តនៅឆ្នាំ ២០០៧ បានរៀបចំសៀវភៅសិក្សាកុំព្យូទ័រ "បំណិនជីវិត បពស" (ដែលជាការណែនាំឲ្យស្គាល់ពី បពស សម្រាប់សិស្សថ្នាក់ទី ១០ តាមរយៈការប្រើប្រាស់កម្មវិធីកុំព្យូទ័រជាភាសាខ្មែរ) បានបណ្តុះបណ្តាលគ្រូបង្រៀន និងបានសហការជាមួយនឹងដៃគូនានារបស់ក្រសួង ក្នុងការធ្វើឲ្យមានការឯកភាពគ្នាក្នុងការបណ្តុះបណ្តាលពីការប្រើប្រាស់កុំព្យូទ័រនៅតាមវិទ្យាល័យ ។

អាំងឌីការទ័រស្តីពីកម្រិតនៃការប្រើប្រាស់ បពស ក្នុងវិស័យអប់រំនៅប្រទេសកម្ពុជានៅពេលបច្ចុប្បន្ន (ដែលជាលទ្ធផលបានមកពីការសិក្សាស្រាវជ្រាវផ្នែក បពស ក្នុងវិស័យអប់រំរបស់កម្មវិធីសាលារៀនបើកចំហនៅឆ្នាំ ២០០៩) គឺជាចំណុចចាប់ផ្តើមរបស់ផែនការគោលនេះ។

ជាទូទៅ នៅដំណាក់កាលដំបូងនៃការអភិវឌ្ឍ បពស ការប្រើប្រាស់កុំព្យូទ័រនៅក្នុងក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមដោយឯករាជ្យនៅតាមនាយកដ្ឋាននីមួយៗ ដោយសារតែនាយកដ្ឋានទាំងនោះ ត្រូវការប្រើប្រាស់កុំព្យូទ័រជាចាំបាច់ និងនៅតាមសាលារៀនដែលទទួលបានជំនួយម៉ាស៊ីនកុំព្យូទ័រ ។ បច្ចុប្បន្ននេះ ក្រសួងបានឈានចូលដំណាក់កាលថ្មី ដែលតម្រូវឲ្យមានការកំណត់គោលនយោបាយ និងការគ្រប់គ្រង បពស ឲ្យកាន់តែជាក់ច្បាស់ ដើម្បីឲ្យការប្រើប្រាស់ បពស មានការឯកភាពគ្នា និងដើម្បីឲ្យការបណ្តុះបណ្តាលសិស្ស និងការគ្រប់គ្រងកាន់តែមានប្រសិទ្ធភាព ។ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ត្រូវបានស្នើឲ្យចូលរួមសហការជាមួយក្រសួងក្នុងក្របខណ្ឌនៃផែនការគោលនេះ ។ ផែនការគោលនេះ បានដាក់បញ្ចូលនូវគម្រោង បពស ដែលដៃគូអភិវឌ្ឍន៍កំពុងអនុវត្តនៅពេលបច្ចុប្បន្ន ហើយផែនការគោលនេះ នឹងជួយតម្រង់ទិសដៅកម្មវិធី និងកិច្ចសហប្រតិបត្តិការថ្មីៗនាពេលអនាគត ។

ការចំណាយតភ្ជាប់បណ្តាញអ៊ីនធឺណិតដើម្បីប្រើប្រាស់សម្រាប់កិច្ចការរដ្ឋបាលអប់រំ និងក្នុងគោលបំណងអប់រំផ្សេងទៀត ដែលជាឧបសគ្គចម្បងមួយរារាំងដល់ការប្រើប្រាស់ បពស ក្នុងវិស័យអប់រំ ត្រូវបានលុបបំបាត់នៅក្នុងឆ្នាំ ២០០៩ ក្រោយពីមានការជួយឧបត្ថម្ភពីក្រុមហ៊ុនមិត្តហ្វូន ដែលបានធានាផ្តល់ការតភ្ជាប់បណ្តាញអ៊ីនធឺណិតដោយពុំគិតប្រាក់ជាអចិន្ត្រៃយ៍ជូនគ្រប់ការិយាល័យរដ្ឋបាលទាំងអស់របស់ក្រសួង សាលារៀន សាកលវិទ្យាល័យសាធារណៈ និងសាលាគរុកោសល្យទូទាំងប្រទេស ។

## ៣. គោលនយោបាយកំពុងអនុវត្ត

នៅខែ មករា ឆ្នាំ ២០០៥ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តឯកសារ "គោលនយោបាយ និងយុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងការអប់រំនៅកម្ពុជា" ដែលជាគោលនយោបាយដឹកនាំការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ (បពស) ក្នុងវិស័យអប់រំ ដោយបានដាក់ចេញនូវគោលដៅការងារសំខាន់ៗដែលកម្ពុជាត្រូវបំពេញ ដើម្បីឲ្យការបញ្ចូលបច្ចេកវិទ្យាក្នុងការបង្រៀន និងរៀននៅតាមអនុវិស័យអប់រំទាំងអស់ អាចសម្រេចទៅបានដោយជោគជ័យ ។ គោលនយោបាយនេះបានដាក់បញ្ចូលគោលនយោបាយសំខាន់ៗរបស់ក្រសួងដែលមាននាពេលនោះ ជាពិសេសគឺផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា (EFA) និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំបច្ចុប្បន្នភាព និងច្បាប់ស្តីពីការអប់រំ (ខែធ្នូ ឆ្នាំ ២០០៧) ដែលបានអនុម័តនៅក្រោយគោលនយោបាយ បពស ឆ្នាំ ២០០៥ ក៏មានទិសដៅស្របគ្នានឹងគោលនយោបាយ បពស ឆ្នាំ ២០០៥ នេះផងដែរ ។

ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ២០០៣ - ២០១៥ បានកំណត់ថា ៖

*"គោលនយោបាយ បពស រួមមាន ៖ (ក) ការពង្រីកបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ឲ្យក្លាយជាឧបករណ៍បង្រៀន និងរៀន ។ (ខ) ជាមធ្យោបាយដើម្បីបង្កើនការគ្រប់គ្រង និងផលិតភាពសេវាអប់រំ ដោយអភិវឌ្ឍការគ្រប់គ្រង ចំណេះដឹង ទំនាក់ទំនង និងការបែងចែកព័ត៌មាន ។ និង (គ) ពង្រីកឱកាសអប់រំពីចម្ងាយ ជាពិសេសសម្រាប់ក្រុមជួបការលំបាកនៅក្នុងតំបន់ដាច់ស្រយាល ។ គោលដៅរួមនឹងធានាថា ការប្រកួតប្រជែងអន្តរជាតិរបស់កម្ពុជានៅក្នុងសេដ្ឋកិច្ចផ្អែកលើចំណេះដឹងក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងពិភពលោកដែលរីកចម្រើន" ។*

យុទ្ធសាស្ត្រ បពស ដែលជាក់ច្បាស់ គឺកំពុងស្ថិតនៅក្នុងដំណើរការនៃការបញ្ចប់នៅឡើយ ។ យុទ្ធសាស្ត្រសំខាន់ៗរួមមាន ៖ (ក) បញ្ចូលបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ទៅក្នុងការអប់រំ និងបណ្តុះបណ្តាល ដោយចាប់ផ្តើមនៅតាមគ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងសាលាមធ្យមសិក្សាដែលបានជ្រើសរើស ។ (ខ) ជ្រើសរើសកម្មវិធីលើកកម្ពស់កម្មវិធីសិក្សា ជាពិសេសកម្មវិធីមួយចំនួនតូចដែលទាក់ទង ដោយមិនគ្រាន់តែបង្ហាញនូវការវិនិយោគដ៏សំខាន់នៅក្នុងគ្រឿងបរិក្ខារ បុគ្គលិក និងសម្ភាររូបវន្តដែលបានលើកឡើង ។ និង (គ) កម្មវិធីមូលដ្ឋានបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ សម្រាប់ក្រុមជួបការលំបាកទាំងឡាយនៅក្នុងសង្គម ដើម្បីធានាឲ្យមានការធ្វើសមាហរណកម្មពួកគេទៅក្នុងការអប់រំក្នុងប្រព័ន្ធ ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក៏បានកំណត់ពីតម្រូវការនៃការ (ក) ផ្តល់ការបណ្តុះបណ្តាល បពស ដល់គ្រូឧទ្ទេស គ្រូបង្រៀន និងសិស្ស (ខ) ប្រើប្រាស់ បពស ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន (គ) ពង្រីកបច្ចេកវិទ្យា និងរចនាសម្ព័ន្ធ បពស និង (ឃ) ប្រើប្រាស់កុំព្យូទ័រក្នុងការគ្រប់គ្រងសាលារៀន

តាមដាន និងការគ្រប់គ្រងហិរញ្ញវត្ថុ ដោយប្រើប្រាស់ បពស ដើម្បីបង្កើនប្រសិទ្ធភាពសាលារៀន ។ ឯកសារទាំងពីរនេះ បានគ្រោងទុកថវិកាមួយចំនួនធំដើម្បីអភិវឌ្ឍ បពស ។

ជាចុងក្រោយ មាត្រា ២៨ នៃច្បាប់ស្តីពីការអប់រំ ដែលបានប្រកាសឲ្យប្រើកាលពីខែ ធ្នូ ឆ្នាំ ២០០៧ បានចែងថា ៖

> *"រដ្ឋត្រូវលើកកម្ពស់ និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ ការច្នៃប្រឌិត និងការផលិតដែលមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងស្របតាមសកលភាវូបនីយកម្ម ដើម្បីលើកស្ទួយសមត្ថភាពធនធានមនុស្ស និងជំរុញការអភិវឌ្ឍជាតិ ។*
>
> *ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់គោលការណ៍ស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំគ្រប់ភូមិសិក្សា នៃប្រព័ន្ធអប់រំកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល" ។*

វត្ថុបំណងនៃផែនការគោលនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ដែលបានក្លាយជាចំណែកមួយដ៏សំខាន់នៃផែនការអភិវឌ្ឍន៍របស់ក្រសួងអប់រំ យុវជន និងកីឡា និងបានធានាថា បច្ចេកវិទ្យាពាក់ព័ន្ធនឹងត្រូវយកមកអនុវត្ត ប្រសិនបើបច្ចេកវិទ្យាទាំងនោះអាចជួយទ្រទ្រង់ដល់យុទ្ធសាស្ត្ររបស់ក្រសួង។ វត្ថុបំណងទាំងនេះ នឹងត្រូវអនុវត្ត តាមរយៈផែនការប្រតិបត្តិប្រចាំឆ្នាំ របស់ក្រសួង អយក ដោយនាយកដ្ឋានពាក់ព័ន្ធនឹងបញ្ចូល បពស ក្នុងដំណើរការកសាងផែនការរបស់ខ្លួន ។

# ៤. គោលដៅរបស់ផែនការគោល

ផែនការគោលនេះ មានគោលដៅជួយដល់កិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចឲ្យបាននូវគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា (EFA) និងជួយឲ្យការគ្រប់គ្រងការអប់រំ និងកិច្ចការរដ្ឋបាលកាន់តែមានប្រសិទ្ធផល និងប្រសិទ្ធភាព តាមរយៈការប្រើប្រាស់គ្រប់ទម្រង់របស់ បពស និងពហុព័ត៌មាន ។ ផែនការនេះក៏នឹងត្រូវដើរតួនាទីជាត្រីវិស័យគោល ដើម្បីជួយតម្រង់ទិសការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ បពស ក្នុងវិស័យអប់រំផងដែរ ។

**គោលដៅរបស់ផែនការគោល រួមមាន ៖**

- បង្កើនឱកាសទទួលបានការអប់រំមូលដ្ឋាន ការអប់រំថ្នាក់ឧត្តមសិក្សា និងការអប់រំពេញមួយជីវិតទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ តាមរយៈការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ធ្វើជាមធ្យោបាយបន្ថែមក្នុងការផ្ដល់ការអប់រំ ។
- បង្កើនភាពពាក់ព័ន្ធ និងប្រសិទ្ធភាពនៃការអប់រំសម្រាប់ទាំងអស់គ្នា តាមរយៈការប្រើប្រាស់សក្ដានុពលនៃ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ធ្វើជាឧបករណ៍ចម្បងក្នុងការលើកកម្ពស់គុណភាពបង្រៀន និងរៀន ។
- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ចាំបាច់សម្រាប់អ្នកបញ្ចប់ការសិក្សា ដើម្បីទទួលបានការងារធ្វើនៅក្នុងសង្គមដែលពឹងផ្អែកលើចំណេះដឹង និងចំណេះធ្វើ ដើម្បីធានាថាកម្ពុជាអាចប្រកួតប្រជែង និងធ្វើសហប្រតិបត្តិការជាមួយបណ្ដាញក្នុងពិភពលោក ។
- បង្កើនប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិក្នុងការងារគ្រប់គ្រងក្រសួង និងសាលារៀន ។

---

# ៥. គោលបំណងជាក់លាក់

ដើម្បីជួយសម្រួលដល់ការអនុវត្តផែនការគោល ផែនអន្តរាគមន៍នីមួយៗ មានអនុផែនដែលមានកំណត់ពីគោលបំណង និងលទ្ធផលយ៉ាងជាក់លាក់ ។

ផែនអន្តរាគមន៍ រួមមាន ៖

- ការអប់រំចំណេះទូទៅ
- ការអប់រំថ្នាក់ឧត្តមសិក្សា
- ការបណ្ដុះបណ្ដាលគ្រូបង្រៀន
- ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ
- ការគ្រប់គ្រងក្រសួង និងការគាំទ្រ បពស ក្នុងវិស័យអប់រំ

## ៥.១. ការអប់រំចំណេះទូទៅ

គោលដៅនៃផែនការគោលចំពោះការអប់រំចំណេះទូទៅ គឺធ្វើការឆ្លើយតបទៅនឹងចក្ខុវិស័យរយៈពេលវែង (១០ ឆ្នាំ) ដែលតម្រូវឲ្យសិស្សដែលបញ្ចប់ថ្នាក់មធ្យមសិក្សា ត្រូវតែមានបំណិនវិជ្ជាជីវៈផ្អែកលើ បពស

និងបំណិនត្រិះរិះពិចារណា ដែលនឹងជួយឲ្យពួកគេអាចសម្របខ្លួនចូលទៅក្នុងទីផ្សារការងារបានឆាប់រហ័ស ឬអាចប្រឈមមុខដោយមានការជឿជាក់ជាមួយនឹងការសិក្សានៅសាកលវិទ្យាល័យ ។ ផ្អែកលើចក្ខុវិស័យនេះ បុគ្គលិកបង្រៀន បុគ្គលិកមិនបង្រៀន និងបុគ្គលិករដ្ឋបាលរបស់អនុផែនអប់រំចំណេះទូទៅ នឹងបញ្ចូល បពស ក្នុងការបំពេញកិច្ចការរបស់ពួកគេជាពិសេសនៅក្នុងការផ្តល់ការអប់រំដល់សិស្ស ។

ការបញ្ចូល បពស ក្នុងដំណើរការគរុកោសល្យឲ្យបានស៊ីជម្រៅ ត្រូវការពេលប្រហែលជា ១០ ឆ្នាំ ប៉ុន្តែដោយសារក្រសួងបានផ្តោតលើការបណ្តុះបណ្តាលអាជីព និងការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យអប់រំ (និងដោយសារថា បពស ជាមុខវិជ្ជាទីមួយនៃមុខវិជ្ជាជីវៈជម្រើសនៅក្នុងការអប់រំចំណេះទូទៅ) ការសម្រេចចិត្តជាយុទ្ធសាស្ត្រ ត្រូវបានធ្វើឡើងដើម្បីពន្លឿនការអនុវត្តវគ្គសិក្សា បពស សម្រាប់សិស្សដើម្បីសម្រេចគោលដៅរយៈពេល ១០ ឆ្នាំឲ្យបានក្នុងរយៈពេល ៥ ឆ្នាំខាងមុខនេះ។

**គោលបំណង ១.១៖** ផ្តល់ឲ្យសិស្សដែលបានបញ្ចប់ការអប់រំថ្នាក់មធ្យមសិក្សានូវបំណិនវិជ្ជាជីវៈផ្អែកលើ បពស ដែលជាតម្រូវការចាំបាច់សម្រាប់ទីផ្សារការងារ ឬដើម្បីទទួលបានភាពជោគជ័យនៅក្នុងការសិក្សានៅថ្នាក់ឧត្តមសិក្សា និងដើម្បីឲ្យពួកគេអាចនឹងទទួលបានអត្ថប្រយោជន៍ជានិរន្តរពីការអប់រំពេញមួយជីវិត

**លទ្ធផល ១.១.១៖** វគ្គបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្អែកលើ បពស និងជំនាញត្រៀមចូលសាកលវិទ្យាល័យ ត្រូវបានផ្តល់ជាប្រព័ន្ធនៅតាមវិទ្យាល័យ

កម្មវិធីសិក្សា បពស ពីរប្រភេទ នឹងត្រូវរៀបចំដាក់បញ្ចូលក្នុងប្រព័ន្ធអប់រំ ៖

(i) កម្មវិធីសិក្សាបំណិនវិជ្ជាជីវៈផ្អែកលើ បពស សម្រាប់សិស្សថ្នាក់ទី ១០ - ជាកម្មវិធីមូលដ្ឋាន ដើម្បីណែនាំសិស្សឲ្យស្គាល់ពីសមត្ថភាពវិជ្ជាជីវៈ។

(ii) កម្មវិធីអប់រំវិជ្ជាជីវៈជម្រើស បំណិនវិជ្ជាជីវៈផ្អែកលើ បពស សម្រាប់សិស្សថ្នាក់ទី ១១ និងថ្នាក់ទី ១២ - ជាវគ្គសិក្សាជម្រើស ដែលនឹងផ្តល់អ្នកសិក្សានូវជំនាញ បពស មូលដ្ឋានសម្រាប់កិច្ចការរដ្ឋបាល ការងារ និងទំនាក់ទំនង ។

វគ្គសិក្សាសម្រាប់សិស្សថ្នាក់ទី ១០ និងថ្នាក់ទី ១១ នឹងផ្តោតលើការបណ្តុះបណ្តាលដូចជា ជំនាញប្រើប្រាស់កុំព្យូទ័រសម្រាប់កិច្ចការរដ្ឋបាល និងទំនាក់ទំនង ។ កម្មវិធី និងសម្ភារសិក្សា នឹងជួយអភិវឌ្ឍជំនាញបច្ចេកទេស ចំណេះដឹង និងជំនាញក្នុងការទំនាក់ទំនង ដែលជាជំនាញត្រូវការជាចាំបាច់ក្នុងការប្រមូល រៀបចំ គ្រប់គ្រង និងបង្ហាញព័ត៌មានខុសៗគ្នាទៅតាមអ្នកប្រើប្រាស់នីមួយៗ ។

វគ្គសិក្សាសម្រាប់សិស្សថ្នាក់ទី ១២ នឹងបន្តអភិវឌ្ឍជំនាញទាំងនេះបន្ថែមទៀត តាមរយៈការប្រើប្រាស់សម្ភារឧបទេសថ្មី ព្រមទាំងផ្តល់ឲ្យសិស្សនូវឱកាសទទួលបានការងារផ្សេងៗ ដែលពាក់ព័ន្ធ បពស ដែលអាចនឹងជួយឲ្យសិស្សកសាងអាជីពការងាររបស់ពួកគេ តាមរយៈការជួយឲ្យពួកគេធ្វើការសម្រេចចិត្តដែលត្រឹមត្រូវ និងពេញលេញ ។

វគ្គសិក្សាអស់ទាំងនេះ នឹងបង្រៀនសិស្សពីការប្រើប្រាស់កម្មវិធីកុំព្យូទ័រ ដែលត្រូវបានបកប្រែជាភាសាខ្មែរទាំងស្រុង និងត្រូវបានកែសម្រួលឲ្យសមស្របតាមវប្បធម៌របស់ខ្មែរ ។

**អាំងឌីកាទ័រ** ៖ នៅឆ្នាំ ២០១៣ សិស្សនៅតាមសាលារៀនដែលមានកម្មវិធីសិក្សាកុំព្យូទ័រ នឹងទទួលបានបំណិនវិជ្ជាជីវៈផ្អែកលើ បពស ពីសាលារៀនតាមរយៈវគ្គសិក្សាបំណិនជីវិត សម្រាប់សិស្សថ្នាក់ទី ១០ ឬវគ្គសិក្សាវិជ្ជាជីវៈជម្រើស សម្រាប់សិស្សថ្នាក់ទី ១១ និងថ្នាក់ទី ១២ ។

**គោលបំណង ១.២៖** ការកែលម្អជំនាញគរុកោសល្យរបស់គ្រូបង្រៀន និងប្រសិទ្ធភាពក្នុងការផ្តល់សេវាអប់រំឲ្យកាន់តែល្អប្រសើរ

**លទ្ធផល ១.២.១៖** គ្រូបង្រៀនថ្នាក់មធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្អែកលើ បពស

ដើម្បីឲ្យសិស្សថ្នាក់មធ្យមសិក្សាទុតិយភូមិអាចទទួលបានបំណិនវិជ្ជាជីវៈផ្អែកលើ បពស គ្រូបង្រៀនដែលកំពុងបម្រើការងារនៅថ្នាក់មធ្យមសិក្សា ត្រូវតែឆ្លងកាត់ការបណ្តុះបណ្តាលបន្ថែម ។ ការធ្វើវិក្រឹតការនេះ នឹងជួយកែលម្អជំនាញក្នុងការបង្រៀន និងជំនាញរដ្ឋបាល ។ ប៉ុន្តែការបណ្តុះបណ្តាលគ្រូបង្រៀនឲ្យបានទាំងអស់ក្នុងរយៈពេល ៥ ឆ្នាំដំបូងនៃផែនការគោលនេះ មិនអាចធ្វើទៅបានឡើយ ហេតុនេះ អាទិភាពនឹងផ្តល់ជូនដល់គ្រូបង្រៀនមកពីសាលារៀនដែលមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ។

**អាំងឌីកាទ័រ** ៖ នៅឆ្នាំ ២០១៣ គ្រូបង្រៀនថ្នាក់មធ្យមសិក្សាទុតិយភូមិចំនួន ៩០ ភាគរយ ដែលបម្រើការងារនៅតាមសាលារៀនដែលមានកម្មវិធីសិក្សាកុំព្យូទ័រ បានទទួលការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្អែកលើ បពស ។

## ៥.២. ការអប់រំថ្នាក់ឧត្តមសិក្សា

មានការរំពឹងទុកថា ការប្រើប្រាស់កុំព្យូទ័រ និងការចូលប្រើប្រាស់ព័ត៌មាននៅថ្នាក់ឧត្តមសិក្សា នឹងមានការកើនឡើងជាលំដាប់ នៅក្នុងរយៈពេល ១០ ឆ្នាំខាងមុខ ។ និស្សិតភាគច្រើនដែលចូលសិក្សានៅតាមសាកលវិទ្យាល័យ នឹងទទួលបានការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្អែកលើ បពស និងជំនាញត្រៀមចូលសាកលវិទ្យាល័យនៅឆ្នាំ ២០១៣ ហើយនៅឆ្នាំ ២០១៥ និស្សិតទាំងអស់នឹងទទួលបានការបណ្តុះបណ្តាលនេះ ។ ការបណ្តុះបណ្តាលបន្ថែមនៅឆ្នាំសិក្សាមូលដ្ឋាននៅសាកលវិទ្យាល័យ នឹងបញ្ចូលការបណ្តុះបណ្តាលពីការប្រើប្រាស់ បពស កម្រិតខ្ពស់ សម្រាប់ការទំនាក់ទំនង ដោយធ្វើការលម្អិតពីបច្ចេកវិទ្យាដែលប្រើប្រាស់តាមដែលអាចធ្វើទៅបានដោយប្រើឧបករណ៍ដែលនឹងមាននាពេលនោះ ។ ហេតុនេះ នៅក្នុងអំឡុងពេល ៥ ឆ្នាំនៃផែនការនេះ ប្រការដែលសំខាន់ គឺត្រូវធ្វើយ៉ាងណាឲ្យនិស្សិតទាំងអស់ដែលបានបញ្ចប់ការសិក្សាឆ្នាំទីមួយនៅសាកលវិទ្យាល័យ បានទទួលជំនាញទំនាក់ទំនងដែលប្រើប្រាស់ បពស និងជំនាញវិជ្ជាជីវៈដទៃៗទៀត ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើង និងការរំពឹងទុករបស់និស្សិត សាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា នឹងត្រូវប្រើប្រាស់ បពស ជាប្រព័ន្ធនៅក្នុងការបង្រៀន ចែករំលែកព័ត៌មានជាមួយនិស្សិត ជំរុញការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល និងវាយតម្លៃការសិក្សារបស់និស្សិត ។ ហេតុនេះ ផែនការគោលនេះ នឹងត្រូវធានាថា សាស្ត្រាចារ្យ

ទាំងអស់មិនត្រឹមតែមានលទ្ធភាពប្រើប្រាស់កុំព្យូទ័រប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវដឹងផងដែរពីរបៀបប្រើប្រាស់ បពស ដើម្បីលើកកម្ពស់ជំនាញរដ្ឋបាល និងគរុកោសល្យ ។

ការសិក្សាពីចម្ងាយ និងបើកទូលាយ (ODL) នឹងកាន់តែត្រូវបានទទួលស្គាល់ និងក្លាយជាជម្រើសដែលអាចទទួលយកបានសម្រាប់និស្សិតដែលមិនអាចបានទទួលការអប់រំដោយផ្ទាល់ ។ ផែនការគោលនេះនឹងផ្តល់ឧបករណ៍ និងចំណេះដឹងនានា ដើម្បីធានាថា ODL ត្រូវបានគ្រប់គ្រង និងដាក់បញ្ចូលឲ្យបានទូលំទូលាយនៅតាមសាកលវិទ្យាល័យ និងដើម្បីកាត់បន្ថយឧបសគ្គបច្ចេកទេសទាំងឡាយដែលអាចនឹងមានក្នុងសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនេះ។

ការសិក្សាពីសមិទ្ធិលទ្ធភាពនឹងត្រូវរៀបចំធ្វើឡើង ដើម្បីកំណត់ពីពេល និងរបៀបបង្កើតសាកលវិទ្យាល័យជាតិបើកទូលាយ ដើម្បីបម្រើសង្គមជាតិទាំងមូល និងក្រុង-ខណ្ឌ-ស្រុកទាំងឡាយដែលមានថាមពលអគ្គិសនី និងសេវាអ៊ីនធឺណិតប្រើប្រាស់។

ក្រសួង និងបណ្តាសាកលវិទ្យាល័យទាំងឡាយនឹងអនុម័តប្រើប្រាស់ស្តង់ដារអន្តរជាតិក្នុងការធ្វើឌីជីថលភាវូបនីយកម្ម និងការផ្លាស់ប្តូរឯកសារ និងអត្ថបទបោះផ្សាយដោយគ្រឹះស្ថានសិក្សានានា ។ តំបន់បណ្តាញអេឡិចត្រូនិក ដែលគ្រប់គ្រងដោយក្រសួង នឹងត្រូវបង្កើតឡើង ដើម្បីធានាថាឯកសារដែលចេញផ្សាយដោយក្រសួង និងបណ្តាសាកលវិទ្យានានា អាចនឹងរុករកបាន និងផ្លាស់ប្តូរជាសាធារណៈ ។

**គោលបំណង ២.១៖** លើកកម្ពស់ជំនាញគរុកោសល្យរបស់បុគ្គលិកបង្រៀន និងប្រសិទ្ធភាពរបស់បុគ្គលិកមិនបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា (HEI)

**លទ្ធផល ២.១.១៖** ការបណ្តុះបណ្តាលជំនាញ បពស ដល់សាស្ត្រាចារ្យ និងបុគ្គលិកថ្នាក់ឧត្តមសិក្សា ត្រូវបានធ្វើនៅគ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់

ដើម្បីសម្រេចនូវលទ្ធផលនេះ ក្រសួង អយក នឹងត្រូវផ្តល់ការគាំទ្រដោយផ្ទាល់ដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈទាំងអស់ និងត្រូវចេញសេចក្តីណែនាំ និងកំណត់ស្តង់ដារដល់គ្រឹះស្ថានឧត្តមសិក្សាឯកជនទាំងអស់ ស្តីពីការធ្វើវិក្រឹតការបុគ្គលិកវិជ្ជាជីវៈទាំងអស់ ទាំងបុគ្គលិកវិជ្ជាជីវៈអប់រំ និងបុគ្គលិកវិជ្ជាជីវៈសុទ្ធសាធ ។

**អាំងឌីកាទ័រ** ៖ បុគ្គលិកបង្រៀន និងបុគ្គលិករដ្ឋបាលទាំងអស់នៅតាមគ្រឹះស្ថានឧត្តមសិក្សាបានទទួលបំណិនវិជ្ជាជីវៈផ្អែកលើ បពស នៅឆ្នាំ ២០១៣ ។ សាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សាដឹងពីរបៀបប្រើប្រាស់បំណិនទាំងនេះ នៅក្នុងកិច្ចការគរុកោសល្យ និងវិជ្ជាជីវៈ នៅឆ្នាំ ២០១៣ ។

**គោលបំណង ២.២៖** ធ្វើការត្រៀមលក្ខណៈជាប្រព័ន្ធឲ្យនិស្សិតដែលបញ្ចប់ថ្នាក់ឧត្តមសិក្សានៅកម្ពុជាមានបំណិនវិជ្ជាជីវៈផ្អែកលើ បពស ដែលចាំបាច់សម្រាប់តម្រូវការទីផ្សារការងារ ឬបន្តការសិក្សាទៅមុខទៀត

**លទ្ធផល ២.២.១៖** និស្សិតបានទទួលការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្អែកលើ បពស

យោងតាមផែនការគោលនេះ សិស្សដែលនឹងចូលសិក្សានៅសាកលវិទ្យាល័យនៅឆ្នាំ ២០១២ នឹងមិនអាចទទួលបានការបណ្តុះបណ្តាល បពស នៅថ្នាក់ទី ១០ បានគ្រប់គ្នានោះទេ ដោយសារថា

ផែនការគោលនេះនៅតែកំពុងអនុវត្តនៅឡើយ ។ សិស្សទាំងនេះ នឹងទទួលបានការបណ្ដុះបណ្ដាលបំណិនវិជ្ជាជីវៈនៅគ្រឹះស្ថានឧត្តមសិក្សា ។ ការបណ្ដុះបណ្ដាលបំណិនវិជ្ជាជីវៈផ្អែកលើ បពស នឹងត្រូវផ្ដល់នៅឆ្នាំសិក្សាមូលដ្ឋាន តាមសេចក្ដីណែនាំដែលចេញដោយក្រសួង និងអនុវត្តតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

**អាំងឌីកាទ័រ** ៖ នៅឆ្នាំ ២០១៣ នឹងមាននិស្សិត ១០០ ភាគរយ ដែលបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋានពីសាកលវិទ្យាល័យ ទទួលបានបំណិនវិជ្ជាជីវៈផ្អែកលើ បពស ។

**គោលបំណង ២.៣៖** បង្កើតយន្តការ និងរចនាសម្ព័ន្ធដែលធ្វើទៅបាន និងមានប្រសិទ្ធភាព ក្នុងការផ្ដល់ការគាំទ្រ និងគ្រប់គ្រងការសិក្សាពីចម្ងាយ និងបើកទូលាយនៅកម្ពុជា

**លទ្ធផល ២.៣.១៖** លើកកម្ពស់លទ្ធភាពក្រសួង អយក និងគ្រឹះស្ថានឧត្តមសិក្សាក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ការសិក្សាពីចម្ងាយ និងបើកទូលាយ (ODL) និងបច្ចេកវិទ្យាពាក់ព័ន្ធនឹង ODL ដោយប្រើប្រាស់សម្ភារ និងកម្មវិធីជាភាសាខ្មែរ

ក្រោមកិច្ចសម្របសម្រួលរបស់នាយកដ្ឋានឧត្ដមសិក្សា ក្រសួង អយក នឹងបង្កើតក្រុមការងារបណ្ដុះបណ្ដាល ODL បង្កើតសម្ភារ និងកម្មវិធីបណ្ដុះបណ្ដាលជាភាសាខ្មែរ និងបណ្ដុះបណ្ដាលគ្រូឧទ្ទេស ODL ។ ក្រុមការងារនេះនឹងបណ្ដុះបណ្ដាលបុគ្គលិកមួយចំនួនរបស់សាកលវិទ្យាល័យ និងគ្រឹះស្ថានឧត្ដមសិក្សាផ្សេងទៀតពីការគ្រប់គ្រង និងការអភិវឌ្ឍ ODL និងផ្ដល់ការគាំទ្រដល់គ្រឹះស្ថានឧត្ដមសិក្សា ដែលជាក្រុមគោលដៅ ដើម្បីឲ្យអាចចាប់ផ្ដើមផ្ដល់វគ្គ ODL នៅឆ្នាំ ២០១១។

**អាំងឌីកាទ័រ** ៖ បុគ្គលិកមកពីបណ្ដាសាកលវិទ្យាល័យយ៉ាងតិចចំនួន ២៥ ទទួលបានការបណ្ដុះបណ្ដាលពីការបង្កើត ការដាក់ឲ្យដំណើរការ និងការគ្រប់គ្រងកម្មវិធីសិក្សាតាមរយៈអេឡិចត្រូនិក ។

**លទ្ធផល ២.៣.២៖** ក្របខណ្ឌគោលនយោបាយស្ដីពីការសិក្សាពីចម្ងាយ និងបើកទូលាយ ត្រូវបានបង្កើត

ក្របខណ្ឌនេះនឹងត្រូវយកមកប្រើប្រាស់ក្នុងការគ្រប់គ្រង ណែនាំ និងតាមដានប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធី ODL នៅកម្ពុជា ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ខែ ធ្នូ ឆ្នាំ ២០១១ ក្របខណ្ឌគោលនយោបាយស្ដីពី ODL នឹងត្រូវបង្កើត និងអនុម័តជាផ្លូវការដោយក្រសួង អយក ។

**លទ្ធផល ២.៣.៣៖** គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជានឹងផ្ដល់វគ្គសិក្សាតាមរយៈ ODL

ដោយមានការគាំទ្រពីក្របខណ្ឌគោលនយោបាយស្ដីពី ODL ដែលនឹងត្រូវបង្កើតនៅមុនដំណាច់ឆ្នាំ ២០១១ សាកលវិទ្យាល័យនានានឹងចាប់ផ្ដើមបង្កើតវគ្គសិក្សាតាមរយៈ ODL ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ សាកលវិទ្យាល័យនៅកម្ពុជាយ៉ាងតិច ៥ ភាគរយ នឹងមានផ្ដល់វគ្គសិក្សាមួយចំនួនតាមរយៈ ODL ក្នុងក្របខណ្ឌដែលបានកំណត់ ។

**លទ្ធផល ២.៣.៤៖** ការសិក្សាមួយនឹងត្រូវរៀបចំធ្វើឡើង ដើម្បីវាយតម្លៃពីសមិទ្ធិលទ្ធភាព និងកំណត់ពីដំណើរការដែលធ្វើទៅបានក្នុងការបង្កើតសាកលវិទ្យាល័យជាតិបើកទូលាយនៅកម្ពុជា

របាយការណ៍សិក្សាស្រាវជ្រាវមួយដែលនឹងធ្វើឡើងក្រោមការសម្របសម្រួលពីនាយកដ្ឋានឧត្តមសិក្សា នឹងធ្វើការវិភាគលម្អិតពីសមិទ្ធិលទ្ធភាព និងយន្តការដែលអាចធ្វើទៅបាន ក្នុងការបង្កើតសាកលវិទ្យាល័យជាតិបើកទូលាយនៅកម្ពុជា ហើយការសិក្សានេះនឹងត្រូវបញ្ចប់នៅឆ្នាំ ២០១១ ។ ការសិក្សាស្រាវជ្រាវនេះ នឹងធ្វើការសិក្សាស្វែងយល់ពីសាកលវិទ្យាល័យបើកទូលាយនានាដែលមានស្រាប់នៅជុំវិញពិភពលោក ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ ដែលអាចជាគ្រោងគំរូដ៏សមស្របមួយសម្រាប់សាកលវិទ្យាល័យជាតិបើកទូលាយនៅកម្ពុជា ។ គម្រោងគំរូបង្កើតសាកលវិទ្យាល័យបើកទូលាយនេះ នឹងដាក់រួមបញ្ចូលសំណើរចនាសម្ព័ន្ធដែលសមស្រប មុខវិជ្ជាសិក្សាដែលអាចរៀនតាមរយៈ ODL ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ ដៃគូអភិវឌ្ឍន៍ដែលមានសក្ដានុពល ធនធានមនុស្ស ពេលវេលា និងកត្តាផ្សេងៗទៀត ដែលអាចនឹងប៉ះពាល់ដល់សមិទ្ធិលទ្ធភាពរបស់គម្រោង ។ គម្រោងក៏នឹងធ្វើការសិក្សាផងដែរពីការដាក់បញ្ចូលសាកលវិទ្យាល័យបើកទូលាយទៅក្នុងសាកលវិទ្យាល័យសាធារណៈដែលមានស្រាប់ ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ និស្សិតកម្ពុជា នឹងអាចសិក្សាយកសញ្ញាប័ត្រមួយចំនួនពីសាកលវិទ្យាល័យនៅកម្ពុជាតាមរយៈ ODL ។ ក្រសួង អយក ឯកភាពពីលទ្ធភាពដែលធ្វើទៅបានក្នុងការបង្កើតសាកលវិទ្យាល័យបើកទូលាយ ។

**គោលបំណង ២.៤៖** អ្នកសិក្សាស្រាវជ្រាវ និងសាស្ត្រាចារ្យថ្នាក់ឧត្តមសិក្សាអាចចែករំលែក និងចូលប្រើប្រាស់ឯកសារស្រាវជ្រាវ សម្ភារឧបទេស និងធនធានអប់រំផ្សេងៗទៀត និងអាចធ្វើកិច្ចសហការសិក្សាស្រាវជ្រាវជាមួយគ្នា ដោយសារតែការរីកចម្រើនទំនាក់ទំនងទូរគមនាគមន៍រវាងសាកលវិទ្យាល័យ

**លទ្ធផល ២.៤.១៖** មជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិកសម្រាប់រក្សាទុកឯកសារស្រាវជ្រាវ សម្ភារឧបទេស និងធនធានអប់រំសម្រាប់ថ្នាក់ឧត្តមសិក្សា នឹងបើកដំណើរការ

នៅមុនដំណាច់ឆ្នាំ ២០១៣ មជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិកសាធារណៈមួយសម្រាប់ថ្នាក់ឧត្តមសិក្សា នឹងមានតម្កល់ ឬមានដាក់តំណភ្ជាប់ទៅកាន់ឯកសារសិក្សាស្រាវជ្រាវទាំងអស់ដែលមាននៅតាមសាកលវិទ្យាល័យនៅកម្ពុជា និងឯកសារសិក្សាស្រាវជ្រាវផ្សេងៗទៀតអំពីប្រទេសកម្ពុជា ហើយក៏នឹងមានផ្ដល់ជូននូវឯកសារបណ្ដុះបណ្ដាលដែលសាស្ត្រាចារ្យកម្ពុជា អាចយកមកប្រើប្រាស់ជាជំនួយក្នុងការត្រៀមរៀបចំមុខវិជ្ជាបង្រៀន ដោយឥតគិតថ្លៃ ។

មជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិកនេះ នឹងដើរតួនាទីជាឧបករណ៍មូលដ្ឋានមួយ ដើម្បីជួយជំរុញការសិក្សាស្រាវជ្រាវ និងជាឃ្លាំងពុទ្ធិកម្រិតឧត្តមសិក្សាជាភាសាខ្មែរ ។ មជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិកនេះ នឹងមានដាក់បញ្ចូលនូវប្រព័ន្ធគ្រប់គ្រងវគ្គសិក្សាដែលនឹងបើកឲ្យប្រើប្រាស់ជាសាធារណៈ ដោយនៅក្នុងប្រព័ន្ធនេះ នឹងមានផ្ទុកនូវសម្ភារ និងឯកសារបណ្ដុះបណ្ដាលរបស់វគ្គសិក្សានានា ដែលមានផ្ដល់ដោយគ្រឹះស្ថានឧត្តមសិក្សា ជូនអ្នកសិក្សាដោយឥតគិតថ្លៃ ។

**លទ្ធផល ២.៤.២៖** កិច្ចសហការសិក្សាស្រាវជ្រាវនឹងត្រូវចាប់ផ្តើមឲ្យមានសកម្មភាពតាមរយៈការប្រើបណ្តាញបញ្ជូនទិន្នន័យដែលមានល្បឿនលឿនដែលតភ្ជាប់បណ្តាសាកលវិទ្យាល័យទាំងអស់នៅកម្ពុជា

នៅមុនដំណាច់ឆ្នាំ ២០១៣ សាកលវិទ្យាល័យនៅកម្ពុជាប្រមាណជា ៦០ ភាគរយ នឹងត្រូវតភ្ជាប់គ្នាតាមរយៈបណ្តាញអុបទិក ដើម្បីចែករំលែកឯកសារស្រាវជ្រាវ ទំនាក់ទំនងរវាងសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ពីការអប់រំពីចម្ងាយរវាងគ្រឹះស្ថានឧត្តមសិក្សានានា ។ បណ្តាញនេះនឹងត្រូវតភ្ជាប់ជាមួយនឹងបណ្តាញសិក្សាស្រាវជ្រាវអាស៊ីអឺរ៉ុប (TEIN3) ដែលនឹងអាចភ្ជាប់ទៅកាន់សាកលវិទ្យាល័យភាគច្រើននៅតំបន់អឺរ៉ុប និងអាស៊ី ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ ឯកសារស្រាវជ្រាវដែលមាននៅតាមសាកលវិទ្យាល័យនានា និងឯកសារស្រាវជ្រាវពីកម្ពុជា និងសម្ភារឧបទេសសម្រាប់មុខវិជ្ជាសិក្សាថ្នាក់ឧត្តមសិក្សា នឹងមាននៅលើបណ្តាញអ៊ីនធឺណិត ។

**គោលបំណង ២.៥៖** ឯកសារស្រាវជ្រាវ និងឯកសាររដ្ឋបាលនៃគ្រឹះស្ថានឧត្តមសិក្សា ត្រូវបានធ្វើស្តង់ដារភាវូបនីយកម្ម

**លទ្ធផល ២.៥.១៖** រាល់ឯកសារ និងធនធានអប់រំដែលក្រសួង និងគ្រឹះស្ថានឧត្តមសិក្សាបានផលិត និងឯកសាររដ្ឋបាលផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សា និងលិខិតឆ្លើយឆ្លងជាមួយក្រសួង នឹងប្រើអ៊ិនកូដ និងទ្រង់ទ្រាយស្តង់ដារ

ការផ្តល់សេវាកម្មអប់រំ និងសេវាកម្មរដ្ឋបាលរបស់ប្រព័ន្ធអប់រំដ៏មានប្រសិទ្ធភាពមួយ ទាមទារឲ្យមាននូវការចែករំលែកធនធានអប់រំ និងឯកសាររដ្ឋបាលនានារវាងផ្ទៃក្នុងក្រសួង និងគ្រឹះស្ថានឧត្តមសិក្សានានា ។ ទិន្នន័យនាពេលបច្ចុប្បន្នកំពុងប្រើប្រាស់ទ្រង់ទ្រាយ និងអ៊ិនកូដខុសៗគ្នា នឹងត្រូវធ្វើស្តង់ដារភាវូបនីយកម្ម ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ ព័ត៌មានដែលចេញផ្សាយដោយសាកលវិទ្យាល័យ និងការផ្លាស់ប្តូរព័ត៌មានរវាងសកលវិទ្យាល័យ និង ក្រសួង អយក នឹងប្រើពុម្ពអក្សរយូនីកូដខ្មែរ និងប្រើទ្រង់ទ្រាយ ODF និង/ឬ ទ្រង់ទ្រាយស្តង់ដារផ្សេងទៀតដែលកំណត់ដោយក្រសួងទាំងស្រុង ១០០ ភាគរយ ។

## ៥.៣. ការបណ្តុះបណ្តាលគ្រូបង្រៀន

ដើម្បីលើកកម្ពស់គុណភាពអប់រំ និងកសាងជំនាញត្រិះរិះពិចារណា និងជំនាញសតវត្សទី ២១ ផ្សេងទៀតរបស់សិស្សនិស្សិត គ្រូបង្រៀនត្រូវបញ្ឈប់សកម្មភាពបង្រៀនតាមបែបអកម្ម និងការតម្រូវឲ្យសិស្សានុសិស្សទន្ទេញចាំមាត់ ហើយចាប់ផ្តើមអនុវត្តការបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល និងត្រូវប្រើវិធីសាស្ត្រគរុកោសល្យអន្តរកម្មជំនួសវិញ ។ មានវិធីសាស្ត្របង្រៀនចំនួនពីរដែលអាចប្រើប្រាស់ បពស ធ្វើជាជំនួយ ៖

- ដាក់បញ្ចូល បពស ទៅក្នុងការបង្រៀន និងរៀន ដើម្បីពង្រឹងគុណភាពនៃការបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស ។

- ប្រើប្រាស់ បពស (ក្នុងករណីនេះ វីដេអូ) ជាឧបករណ៍សម្រាប់ធ្វើការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន តាមរយៈការសិក្សាវិភាគ និងដកស្រង់យកមកធ្វើជាគំរូនូវបច្ចេកទេសគរុកោសល្យល្អ ។

នៅក្នុងអំឡុងពេលនៃការអនុវត្តផែនការគោលនេះ គំរូនៃការប្រើប្រាស់ បពស ទាំងពីរនេះ ត្រូវបានរំពឹងទុកថានឹងធ្វើឲ្យមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ពីមុខវិជ្ជាបង្រៀន ការបង្រៀន និងការរៀននៅតាមសាលារៀននៅកម្ពុជា ដោយចាប់ផ្តើមពីដំណាក់កាលដំបូងបំផុតនៃប្រព័ន្ធអប់រំ ។ ជាលទ្ធផលប្រការនេះនឹងជួយសម្រេចនូវគោលដៅអប់រំថ្នាក់ជាតិ និងជួយដល់ការត្រៀមលក្ខណៈជាទូទៅរបស់សិស្សានុសិស្សក្នុងការចូលសិក្សានៅថ្នាក់ឧត្តមសិក្សា និងការត្រៀមខ្លួនសម្រាប់ទីផ្សារការងារ ។

នៅក្នុងអំឡុងពេលនៃការអនុវត្តផែនការគោលនេះ យើងនឹងឃើញមានការរីករាលដាលនៃការប្រើប្រាស់ បពស ក្នុងសង្គមជាតិទាំងមូល ។ ប្រព័ន្ធអប់រំ និងអ្នកអប់រំដែលជាអ្នកត្រួសត្រាយផ្លូវឲ្យមានការរីករាលដាលនេះ នឹងត្រូវដើរតួនាទីឈានមុខគេក្នុងការផ្សព្វផ្សាយពីប្រសិទ្ធភាព និងការប្រើប្រាស់ដោយត្រឹមត្រូវនូវឧបករណ៍ បពស ។ ដើម្បីធានាថាប្រព័ន្ធអប់រំរបស់កម្ពុជាមានការឈានមុខគេក្នុងដំណើរការនេះ ផែនការគោលរយៈពេល ៥ ឆ្នាំនេះនឹងធានាថាគរុសិស្ស-និស្សិត និងគ្រូបង្រៀនមួយចំនួនធំ (ជាពិសេសគ្រូបង្រៀនថ្នាក់មធ្យមសិក្សាទុតិយភូមិ) មានចំណេះដឹង បពស និងបានទទួលការបណ្តុះបណ្តាលពីគោលការណ៍គរុកោសល្យ និងវិធីសាស្រ្តបង្រៀនសមស្រប ក្នុងការប្រើប្រាស់ បពស ដើម្បីលើកកម្ពស់គុណភាពអប់រំ ។ តាមរយៈការប្រើប្រាស់វីដេអូបណ្តុះបណ្តាលពីទម្លាប់អនុវត្តល្អក្នុងការប្រើប្រាស់ បពស រួមជាមួយនឹងសម្ភារឧបទេស និងវិធីសាស្រ្តបង្រៀនសមស្រប លោកគ្រូអ្នកគ្រូ នឹងអាចមើលឃើញឧទាហរណ៍ដែលសក្តិសមបំផុតក្នុងការដាក់បញ្ចូល បពស ទៅក្នុងថ្នាក់រៀន ។

**គោលបំណង ៣.១៖** គ្រូឧទ្ទេស គរុសិស្ស និងនាយកសាលា លើកកម្ពស់ជំនាញគរុកោសល្យ និងប្រសិទ្ធភាពនៃការបង្រៀនតាមរយៈការប្រើប្រាស់ បពស

**លទ្ធផល ៣.១.១៖** គរុសិស្សនៅតាមសាលាគរុកោសល្យនានាបានទទួលការបណ្តុះបណ្តាលពីការដាក់បញ្ចូល បពស ក្នុងការបង្រៀន

ការបណ្តុះបណ្តាលនឹងផ្តោតលើការផ្តល់ឲ្យលោកគ្រូអ្នកគ្រូនូវជំនាញក្នុងការប្រើប្រាស់កុំព្យូទ័រ និង បពស ផ្សេងទៀត ធ្វើជាឧបករណ៍ជំនួយដ៏មានប្រសិទ្ធភាពក្នុងការ (ក) លើកកម្ពស់ការបង្រៀននៅក្នុងថ្នាក់ (ខ) រុករកព័ត៌មានសម្រាប់ត្រៀមបង្រៀន និង (គ) សម្របសម្រួលការងាររវាងថ្នាក់រៀន និងរដ្ឋបាលរបស់សាលារៀន ។ ជារួម ពួកគាត់នឹងក្លាយជាអ្នកត្រួសត្រាយផ្លូវ ដែលនឹងនាំសិស្សរបស់ខ្លួនចូលក្នុងពិភពឌីជីថលថ្មីមួយ ។

ហេតុនេះ នៅមុនដំណាច់ឆ្នាំ ២០០៩ គរុសិស្សថ្នាក់មធ្យមសិក្សាទុតិយភូមិទាំងអស់ បានទទួលការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈផ្អែកលើ បពស សម្រាប់គ្រូបង្រៀន យ៉ាងតិច ៦០ ម៉ោង ។ នៅមុនដំណាច់ឆ្នាំ ២០១០ គរុសិស្សថ្នាក់មធ្យមសិក្សាបឋមភូមិទាំងអស់ ចាប់ផ្តើមបានទទួលការបណ្តុះបណ្តាលបំណិននេះយ៉ាងតិច ១៤៤ ម៉ោង ហើយនៅមុនដំណាច់ឆ្នាំ ២០១២ គរុសិស្សថ្នាក់

មត្តេយ្យ និងថ្នាក់បឋមសិក្សាទាំងអស់ នឹងចាប់ផ្តើមទទួលបានការបណ្តុះបណ្តាលបំណិនវិជ្ជាជីវៈនេះ យ៉ាងតិច ៦០ ម៉ោង ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ គរុសិស្ស ១០០ ភាគរយ ដែលបញ្ចប់ការសិក្សាពីសាលាគរុកោសល្យនានា នឹងទទួលបានជំនាញវិជ្ជាជីវៈ បពស សម្រាប់គ្រូបង្រៀន ។

**លទ្ធផល ៣.១.២៖** គ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យដាក់បញ្ចូល បពស ក្នុងការបង្រៀន

ការដែលគ្រូឧទ្ទេសមានជំនាញ បពស នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ពួកគាត់ត្រូវចេះប្រើប្រាស់ជំនាញនេះក្នុងការរៀបចំសម្ភារឧបទេសដែលមានលក្ខណៈល្អប្រសើរជាងមុន ហើយត្រូវចេះដាក់បញ្ចូល បពស ក្នុងកម្មវិធីសិក្សារបស់សាលាគរុកោសល្យ ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១០ សាលាគរុកោសល្យទាំងអស់ នឹងមានបំពាក់នូវសម្ភារឧបករណ៍ដែលអាចឲ្យគ្រូឧទ្ទេសរៀបចំសម្ភារឧបទេសអេឡិចត្រូនិក ។ នៅមុនដំណាច់ឆ្នាំ ២០១១ គ្រូឧទ្ទេសទាំងអស់ នឹងបានទទួលការបណ្តុះបណ្តាលពីការដាក់បញ្ចូល បពស ក្នុងកម្មវិធីសិក្សា ។ នៅមុនដំណាច់ឆ្នាំ ២០១៣ ការប្រើប្រាស់ បពស ត្រូវបានដាក់បញ្ចូលក្នុងថ្នាក់រៀន ២០ ភាគរយ នៅតាមសាលាគរុកោសល្យ ។

**លទ្ធផល ៣.១.៣៖** ការអប់រំជំនាញគរុកោសល្យដល់គរុសិស្ស បានត្រូវលើកកម្ពស់ តាមរយៈការប្រើប្រាស់វីដេអូធ្វើជាឧបករណ៍ជំនួយដល់ការបង្រៀន

វីដេអូបណ្តុះបណ្តាលពីទម្លាប់អនុវត្តល្អ នឹងត្រូវប្រើប្រាស់ដើម្បីបង្ហាញពីបច្ចេកទេសផ្សេងៗក្នុងការបង្រៀនមុខវិជ្ជាជាក់លាក់ណាមួយ ដោយផ្តោតលើមុខវិជ្ជាវិទ្យាសាស្ត្រ ។ សម្ភារឧបទេសប្រភេទនេះមួយចំនួន ក៏អាចនឹងប្រើប្រាស់សម្រាប់ធ្វើវិក្រឹតការគ្រូបង្រៀន ( ឧ. តាមរយៈការបណ្តុះបណ្តាលកម្រងសាលារៀន ) ជាពិសេសសម្រាប់គ្រូដែលមិនទាន់មានគុណវុឌ្ឍិគ្រប់គ្រាន់ ដោយសារតែពួកគាត់ទើបនឹងឡើងឋានៈ ហើយនៅមិនទាន់មានចំណេះដឹងគ្រប់គ្រាន់ពីមុខវិជ្ជាដែលពួកគាត់ត្រូវបង្រៀន ។ គោលបំណងនៃការប្រើប្រាស់វីដេអូ គឺដើម្បីបង្ហាញ និងពិភាក្សាអំពីគំរូល្អៗក្នុងការរៀន និងបង្រៀនដែលពាក់ព័ន្ធនឹងគោលការណ៍គរុកោសល្យដែលកំពុងសិក្សានៅក្នុងថ្នាក់រៀន ។

**អាំងឌីកាទ័រ** ៖ នៅដើមឆ្នាំ ២០១១ មុខវិជ្ជាវិទ្យាសាស្ត្រចំនួន ៥០ ភាគរយ ដែលបង្រៀននៅវិទ្យាស្ថានជាតិអប់រំ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ នឹងប្រើប្រាស់វីដេអូធ្វើជាឧបករណ៍ជំនួយក្នុងការបង្រៀន និង ១០០ ភាគរយ នៅមុនដំណាច់ឆ្នាំ ២០១២ ។ នៅដើមឆ្នាំ ២០១១ មុខវិជ្ជាវិទ្យាសាស្ត្រចំនួន ៥០ ភាគរយ នៃសាលាគរុកោសល្យផ្សេងទៀតមានប្រើប្រាស់វីដេអូមួយចំនួនធ្វើជាឧបករណ៍ជំនួយក្នុងការបង្រៀនពីបច្ចេកទេសគរុកោសល្យ ។ សាលាគរុកោសល្យទាំងអស់ ប្រើប្រាស់វីដេអូធ្វើជាឧបករណ៍ជំនួយក្នុងការបង្រៀន នៅមុនដំណាច់ឆ្នាំ ២០១២ ។

**លទ្ធផល ៣.១.៤៖** ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់នាយកសាលា បានត្រូវលើកកម្ពស់តាមរយៈការប្រើប្រាស់វីដេអូធ្វើជាឧបករណ៍ជំនួយដល់ការបណ្តុះបណ្តាល

នាយកសាលានឹងអាចប្រើប្រាស់សម្ភារឧបទេសជាប្រភេទវីដេអូទាំងនេះដើម្បីសិក្សាស្វែងយល់ដោយខ្លួនឯង ឬនៅក្នុងការប្រជុំកម្រងសាលារៀន ។ វីដេអូពិសេសដែលផ្តោតលើការដឹកនាំសាលារៀន នឹងត្រូវរៀបចំឡើងដើម្បីយកទៅប្រើប្រាស់នៅតាមសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំដែលរៀបចំធ្វើនៅរាជធានី-ខេត្ត ថ្នាក់ក្រុង-ខណ្ឌ-ស្រុក នានា ដែលនឹងបើកឱកាសឲ្យមានការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍គ្នាទៅវិញទៅមក ។

**អាំងឌីកាទ័រ** ៖ នៅដើមឆ្នាំ ២០១១ វីដេអូស្តីពីការដឹកនាំសាលារៀន ត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់ធ្វើជាឧបករណ៍ជំនួយដល់ការបណ្តុះបណ្តាល នៅតាមសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំសម្រាប់នាយកសាលារៀន ។

**លទ្ធផល ៣.១.៥៖** កម្មវិធីលើកកម្ពស់សមត្ថភាពគ្រូបង្រៀនកម្រិតបឋមសិក្សាឲ្យទៅជាគ្រូបង្រៀនកម្រិតថ្នាក់អប់រំមូលដ្ឋានបានត្រូវលើកកម្ពស់ តាមរយៈការប្រើប្រាស់វីដេអូធ្វើជាឧបករណ៍ជំនួយដល់ការបណ្តុះបណ្តាល

បញ្ហាប្រឈមដ៏ចម្បងមួយក្នុងការធ្វើកំណែទម្រង់ការអប់រំនៅកម្ពុជាគឺ ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនពីគ្រូបង្រៀនថ្នាក់បឋមសិក្សាឲ្យទៅជាគ្រូបង្រៀនកម្រិតថ្នាក់អប់រំមូលដ្ឋាន (គ្រូបង្រៀនថ្នាក់មធ្យមសិក្សាបឋមភូមិ)។ នៅដើមឆ្នាំ ២០១១ វីដេអូនឹងត្រូវបានប្រើប្រាស់ធ្វើជាឧបករណ៍ជំនួយដល់ការបណ្តុះបណ្តាលមុខវិជ្ជាវិទ្យាសាស្រ្ត នៅក្នុងកម្មវិធីលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ។

**អាំងឌីកាទ័រ** ៖ នៅដើមឆ្នាំ ២០១១ កម្មវិធីលើកកម្ពស់សមត្ថភាពគ្រូបង្រៀន នឹងប្រើប្រាស់វីដេអូមួយចំនួនដើម្បីបង្ហាញពីបច្ចេកទេសគរុកោសល្យ និងបញ្ហាជាក់លាក់មួយចំនួន យ៉ាងតិចបំផុត ៥០ ភាគរយនៃមុខវិជ្ជាវិទ្យាសាស្រ្តទាំងអស់ ។

**គោលបំណង ៣.២៖** វិទ្យាល័យមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិ បពស ដើម្បីបង្រៀន បពស

**លទ្ធផល ៣.២.១៖** វិទ្យាស្ថានជាតិអប់រំរៀបចំបណ្តុះបណ្តាល និងបញ្ជាក់ពីគុណវុឌ្ឍិគ្រូបង្រៀន បពស ដែលមានសមត្ថភាពបង្រៀនកម្មវិធីសិក្សា បពស សម្រាប់ថ្នាក់មធ្យមសិក្សា

ចំណុចពិសេសថ្មីមួយរបស់ផែនការគោលនេះគឺការយកចិត្តទុកដាក់ដោយបើកចំហចំពោះការបណ្តុះបណ្តាលគ្រូជំនាញឯកទេស បពស ដោយគ្រូមួយចំនួនជាគ្រូឯកទេស បពស "សុទ្ធសាធ" (បង្រៀនតែមុខវិជ្ជា បពស) និងមួយចំនួនទៀតមានជំនាញ បពស ជាឯកទេសបន្ទាប់បន្សំ។ ហេតុនេះនៅមុនដំណាច់ឆ្នាំ ២០១០ វិទ្យាស្ថានជាតិអប់រំ នឹងបណ្តុះបណ្តាលគ្រូបង្រៀន បពស យ៉ាងតិច ៣០០ នាក់ ក្នុងមួយឆ្នាំ ដែលក្នុងចំណោមនោះ មានគ្រូឯកទេស បពស សុទ្ធសាធយ៉ាងតិច ៣០ នាក់ និង ២៨០ នាក់ មានជំនាញ បពស ជាឯកទេសបន្ទាប់បន្សំ (ឯកទេសចម្បងរបស់គរុសិស្សទាំងនេះរួមមានគណិតវិទ្យា រូបវិទ្យា ជីវវិទ្យា ភាសាអង់គ្លេស ឬកសិកម្ម)។ គ្រូបង្រៀន បពស ថ្មីទាំងអស់ នឹងត្រូវបណ្តុះបណ្តាលឲ្យចេះបង្ហាត់បង្រៀនសិស្ស និងគ្រូ ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ កម្មវិធីសិក្សា បពស ថ្មី នឹងត្រូវបង្រៀននៅតាមវិទ្យាល័យដែលមានម៉ាស៊ីនកុំព្យូទ័រប្រើប្រាស់ ដោយគ្រូបង្រៀនដែលបានឆ្លងកាត់ការបណ្តុះបណ្តាលជាពិសេសពីវិទ្យាស្ថានជាតិអប់រំ ពីការបង្ហាត់បង្រៀន បពស ។

**គោលបំណង ៣.៣៖** គ្រូបង្រៀនអាចចូលប្រើប្រាស់សម្ភារឧបទេស និងធនធានអប់រំផ្សេងទៀតដែលផលិតដោយ អយក និងគ្រូបង្រៀនដទៃទៀត បានមិនគិតកម្រៃ

**លទ្ធផល ៣.៣.១៖** ឃ្លាំងតម្កល់ឯកសារអប់រំអេឡិចត្រូនិកមួយ នឹងត្រូវបង្កើតឡើងដើម្បីបម្រើដល់ការបណ្តុះបណ្តាល និងសកម្មភាពបង្រៀន

ចំណុចដ៏សំខាន់មួយរបស់ផែនការមេនេះ គឺបង្កើតនូវឃ្លាំងផ្ទុកឯកសារអេឡិចត្រូនិកមួយ (ជាគេហទំព័រ ឬមជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិក) ដែលមានតម្កល់ ឬមានដាក់តំណភ្ជាប់ទៅកាន់សម្ភារឧបទេសដែលគ្រូបង្រៀនបានរៀបចំធ្វើ និងសម្ភារឧបទេសផ្សេងទៀតដែលគ្រូបង្រៀនអាចប្រើប្រាស់ដោយឥតគិតថ្លៃក្នុងការត្រៀមរៀបចំមុខវិជ្ជាបង្រៀន ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ សម្ភារឧបទេស និងឯកសារអប់រំដែលរៀបចំតាក់តែងឡើងដោយគ្រូបង្រៀន និងក្រសួង នឹងមាននៅលើបណ្តាញអ៊ីនធឺណិត ។

## ៥.៤. ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ

នៅក្នុងរយៈពេល ១០ ឆ្នាំខាងមុខ លទ្ធភាពចូលប្រើប្រាស់ និងការប្រើប្រាស់ជាទូទៅនូវសម្ភារសិក្សា បពស នឹងផ្តល់ផលជាវិជ្ជមានទៅលើ (ក) លទ្ធផលនៃការប្រឡងរបស់កម្មវិធីថ្នាក់សមមូលសម្រាប់អ្នកសិក្សាដែលផ្លាស់ពីកម្មវិធីអប់រំក្រៅប្រព័ន្ធមកកម្មវិធីអប់រំក្នុងប្រព័ន្ធ (ខ) សមិទ្ធផលនៅថ្ងៃអនាគតរបស់អ្នកសិក្សានៅក្នុងប្រព័ន្ធអប់រំ និង (គ) ផលិតភាព និងការបង្កើតប្រាក់ចំណូលនៅតំបន់ជនបទ ។ ក្រុមជនជួបការលំបាក នឹងបានទទួលការលើកទឹកចិត្តឲ្យបន្តការសិក្សា ដើម្បីបង្កើនផលិតភាពការងារ និងជីវភាពរស់នៅរបស់ពួកគេ តាមរយៈការប្រើប្រាស់ឧបករណ៍ បពស និងសម្ភារឧបទេសពហុព័ត៌មានដែលពួកគេអាចមានលទ្ធភាពប្រើប្រាស់ មានភាពទំនើបទាន់សម័យ និងមានគុណភាពល្អ នៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ ។ មជ្ឈមណ្ឌលសិក្សាសហគមន៍របស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នឹងផ្តល់សម្ភារឧបទេសដើម្បីបំពេញសេចក្តីត្រូវការសិក្សារៀនសូត្ររបស់អ្នកប្រើប្រាស់នៅតាមមូលដ្ឋាន ដូចជាវីដេអូបណ្តុះបណ្តាលពីការបង្កើតប្រាក់ចំណូល និងកម្មវិធីសិក្សាត្រៀមប្រឡងយកសញ្ញាបត្រនានា និងសម្ភារសិក្សាមុខវិជ្ជាសិក្សាជាក់លាក់មួយចំនួនដោយប្រើកុំព្យូទ័រជាឧបករណ៍ជំនួយ ។ មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវបានរំពឹងថានឹងប្រែក្លាយទៅជាបណ្ណាល័យអេឡិចត្រូនិក ដែលពលរដ្ឋគ្រប់រូបអាច

ចូលប្រើប្រាស់ស្វែងរកព័ត៌មានដែលទាក់ទងនឹងការប្រឡងរបស់កម្មវិធីថ្នាក់សមមូល ឬព័ត៌មានជាក់លាក់ណាមួយដែលអាចនឹងជួយលើកកម្ពស់ជីវភាពរស់នៅ និងប្រាក់ចំណូលរបស់ពួកគេ ។ សម្ភារទាំងនេះ ក៏នឹងត្រូវចែកចាយផងដែរនៅតាមសាលារៀន សាលាគរុកោសល្យ និងនៅតាមទីកន្លែងផ្សេងដែលអាចនឹងមានប្រយោជន៍ ។

ផែនការគោលរយៈពេល ៥ ឆ្នាំនេះ នឹងធានានូវការផលិតវីដេអូបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់ ដែលអាចឆ្លើយតបតាមគោលបំណងនេះ ដូចជាសម្ភារបណ្តុះបណ្តាលសម្រាប់ការត្រៀមប្រឡងថ្នាក់សមមូល (ផ្តោតជាបឋមទៅលើការប្រឡងមធ្យមសិក្សាទុតិយភូមិ) និងសម្ភារបណ្តុះបណ្តាលសម្រាប់កម្មវិធីបង្កើតប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន ។

**គោលបំណង ៤.១៖** ការត្រៀមកម្មវិធីសមមូលថ្នាក់មធ្យមសិក្សាទុតិយភូមិ ជាពិសេសសម្រាប់គ្រូបឋមសិក្សា ត្រូវបានគាំទ្រដោយវីដេអូបណ្តុះបណ្តាល

**លទ្ធផល ៤.១.១៖** គ្រូបឋមសិក្សា និងសិស្សដែលបោះបង់ការសិក្សា នឹងបានទទួលវីដេអូបណ្តុះបណ្តាលដែលមានគុណភាពល្អ ដើម្បីជួយពួកគេក្នុងការត្រៀមប្រឡងកម្មវិធីសមមូលថ្នាក់ទី ១២

ចំនួនសិស្សដែលបានបោះបង់ចោលការសិក្សា និងគ្រូបឋមសិក្សាដែលមានត្រឹមសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ដែលមានបំណងសិក្សាត្រៀមប្រឡងកម្មវិធីសមមូលថ្នាក់ទី ១២ ដែលរៀបចំដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ មានការកើនឡើងជាលំដាប់ ។ នៅមុនដំណាច់ឆ្នាំ ២០១៣ ក្រុមអ្នកសិក្សាដើម្បីត្រៀមប្រឡងកម្មវិធីសមមូលថ្នាក់ទី ១២ ទាំងពីរក្រុមនេះ នឹងអាចប្រើប្រាស់វីដេអូបណ្តុះបណ្តាលដែលមានគុណភាពល្អ និងទំនើបទាន់សម័យ សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រដែលមានក្នុងកម្មវិធីសិក្សា ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ វីដេអូបណ្តុះបណ្តាល នឹងមានសម្រាប់គាំទ្រដល់ផ្នែកដែលពិបាកបំផុតនៃមុខវិជ្ជាវិទ្យាសាស្ត្រនៃកម្មវិធីប្រឡងសមមូលថ្នាក់ទី ១២ ។

**គោលបំណង ៤.២៖** សមាជិកសហគមន៍ ត្រូវបានគាំទ្រក្នុងការពង្រឹងជំនាញបង្កើតប្រាក់ចំណូលតាមរយៈវីដេអូបណ្តុះបណ្តាល

**លទ្ធផល ៤.២.១៖** វីដេអូបណ្តុះបណ្តាលពាក់ព័ន្ធនឹងជំនាញបង្កើតប្រាក់ចំណូល ត្រូវបានផលិត និងចែកចាយ នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍

ដើម្បីឲ្យវីដេអូបណ្តុះបណ្តាលអាចមានលទ្ធភាពជះឥទ្ធិពលទៅលើជំនាញក្នុងការបង្កើតប្រាក់ចំណូល និងជាពិសេស ទៅលើប្រាក់ចំណូលគ្រួសារ ចាំបាច់ត្រូវតែធ្វើការផលិត ចែកចាយ និងប្រើប្រាស់វីដេអូបណ្តុះបណ្តាលដែលពាក់ព័ន្ធនឹងជំនាញនេះ ។ នៅមុនដំណាច់ឆ្នាំ ២០១៣ វីដេអូបណ្តុះបណ្តាលជំនាញបង្កើតប្រាក់ចំណូល នឹងមានយ៉ាងតិច ២៤ ប្រធានបទ ។ វីដេអូទាំងនេះ នឹងត្រូវចែកចាយនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ និងត្រូវប្រើប្រាស់ជាប្រព័ន្ធនៅតាមថ្នាក់សិក្សាពីជំនាញបង្កើតប្រាក់ចំណូល ។

**អាំងឌីកាទ័រ** ៖ នៅមុនដំណាច់ឆ្នាំ ២០១៣ ថ្នាក់សិក្សាពីជំនាញបង្កើតប្រាក់ចំណូលចំនួន ៥០ ភាគរយ នឹងប្រើប្រាស់វីដេអូបណ្តុះបណ្តាលជាឧបករណ៍ជំនួយ ។

**លទ្ធផល ៤.២.២៖** សហគមន៍នៅតាមខេត្តចំនួន ៦ ដែលនៅជាប់ព្រំដែន ហើយដែលពុំមានភ្លើងអគ្គិសនី និងសេវាអ៊ីនធឺណិតប្រើប្រាស់ បានទទួលការប្រើប្រាស់សេវាសិក្សាចល័ត បពស

នៅមុនដំណាច់ឆ្នាំ ២០១៣ ក្រុមយុវជន និងកុមារជួបការលំបាកនៅតាមសហគមន៍ងាយរងគ្រោះនៃខេត្តចំនួន ៦ ដែលនៅជាប់ព្រំដែន គឺខេត្តព្រះវិហារ ឧត្តរមានជ័យ មណ្ឌលគិរី រតនគិរី ស្វាយរៀង និងកោះកុង នឹងមានលទ្ធភាពទទួលបានវីដេអូបណ្តុះបណ្តាលពីជំនាញស្វែងរកប្រាក់ចំណូល និងពីប្រធានបទសំខាន់ៗផ្សេងទៀត តាមរយៈការចាប់ផ្តើមប្រើប្រាស់កុំព្យូទ័រយួរដៃ ម៉ាស៊ីនថតរូបឌីជីថល និងឧបករណ៍ បពស ផ្សេងទៀត ដោយប្រើប្រាស់នូវមធ្យោបាយសិក្សាចល័តដែលមានឈ្មោះថា "រថយន្តសិក្សាចល័ត" ។

**អាំងឌីកាទ័រ** ៖ រថយន្តសិក្សាចល័តចំនួនប្រាំមួយគ្រឿង ត្រូវបានដាក់ពង្រាយ និងបើកដំណើរការនៅតាមបណ្តាខេត្តទាំងប្រាំមួយ ។

## ៥.៥. ការគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួង និងការគាំទ្រ បពស ក្នុងវិស័យអប់រំ

ដើម្បីផ្តល់ការអប់រំឲ្យបានកាន់តែល្អប្រសើរ ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវគ្រប់គ្រង និងវិភាគព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ដែលពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងរដ្ឋបាលអប់រំ បុគ្គលិក និងហិរញ្ញវត្ថុរបស់ក្រសួង ។ យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មាន ត្រូវតែមានជាចាំបាច់ ដើម្បីឲ្យក្រសួងប្រើប្រាស់ ផ្លាស់ប្តូរ វិភាគ និងប្រើព័ត៌មានទាំងនេះដើម្បីជួយសម្របសម្រួលការងាររៀបចំផែនការ និងការគ្រប់គ្រងការអប់រំនៅកម្ពុជា។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលតភ្ជាប់គ្នានេះ នឹងផ្តល់ឲ្យថ្នាក់ដឹកនាំក្រសួង អយក នូវលទ្ធភាពអាចប្រើប្រាស់ព័ត៌មានដែលចាំបាច់ដល់ការធ្វើសេចក្តីសម្រេចចិត្តពីគោលនយោបាយ និងសកម្មភាពអប់រំ បានដោយងាយស្រួល និងដោយផ្ទាល់ ។

ក្នុងអំឡុងពេលប្រាំឆ្នាំខាងមុននេះ ក្រសួងចាំបាច់ត្រូវតែធ្វើសុខដុមនីយកម្ម ស្តង់ដារភាវូបនីយកម្ម និងធ្វើការតភ្ជាប់មូលដ្ឋានទិន្នន័យទាំងអស់របស់ក្រសួង ដែលនឹងនាំឲ្យមានការធ្វើវិមជ្ឈការការប្រមូល និងបញ្ចូលទិន្នន័យ ពីប្រភពរបស់ទិន្នន័យ (សាលារៀន ការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុក និងមន្ទីរ អយក រាជធានី-ខេត្ត ។ល។) ការធានាសុវត្ថិភាពទិន្នន័យ និងការចែកចាយទិន្នន័យទាំងនេះដល់អ្នកដែលចាំបាច់ត្រូវការប្រើប្រាស់ ។ ផែនការគោលនេះ បានស្នើនូវសកម្មភាពជាក់លាក់មួយចំនួនដែលត្រូវបំពេញ ដើម្បីធ្វើស្តង់ដារភាវូបនីយកម្ម ការតភ្ជាប់ និងការធ្វើអន្តរប្រតិបត្តិការទិន្នន័យ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការប្រើប្រាស់កម្មវិធីកុំព្យូទ័រក្នុងការប្រមូល និងគ្រប់គ្រងទិន្នន័យនៅតាមសាលារៀន និងសាលាគរុកោសល្យ និងការបង្កើតរចនាសម្ព័ន្ធក្រសួង ដែលនឹងគាំទ្រដល់ការធ្វើកុំព្យូទ័រភាវូបនីយកម្ម និងដំណើរការគ្រប់គ្រងព័ត៌មាន ។

នៅពេលអនុវត្តផែនការគោលនេះ ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ (ICTEO) នឹងមានតួនាទីក្នុងការគ្រប់គ្រង និងសម្របសម្រួលប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ក្រសួង បន្ថែមលើការទទួលខុសត្រូវបច្ចុប្បន្នរបស់ខ្លួនក្នុងការណែនាំពីការប្រើប្រាស់ បពស ក្នុងវិស័យអប់រំ ។

**គោលបំណង ៥.១៖** ក្រសួង អយក អនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានដែលធ្វើសុខដុមនីយកម្មស្តង់ដារភាវូបនីយកម្ម និងធ្វើការតភ្ជាប់មូលដ្ឋានទិន្នន័យ និងព័ត៌មានរបស់នាយកដ្ឋានចំណុះទាំងអស់

**លទ្ធផល ៥.១.១៖** យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានរបស់ អយក ត្រូវបានកំណត់

យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មាន ដែលនឹងមានបញ្ចូលការធ្វើស្តង់ដារភាវូបនីយកម្មរបៀបផ្លាស់ប្តូរ និងរក្សាទិន្នន័យនៅ អយក វិធានការសុវត្ថិភាពឧបករណ៍ដែលនឹងត្រូវប្រើ និងវគ្គបណ្តុះបណ្តាលស្តង់ដារសម្រាប់បុគ្គលិកក្រសួង នឹងត្រូវអនុម័តដោយ អយក នៅមុនដំណាច់ឆ្នាំ ២០១១ ។

**អាំងឌីកាទ័រ** ៖ អង្គភាពក្រោមឱវាទក្រសួង អយក ទាំងអស់ ចាប់អនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មាន នៅមុនដំណាច់ឆ្នាំ ២០១២ ។

**គោលបំណង ៥.២៖** ការធ្វើស្តង់ដារភាវូបនីយកម្ម និងការធ្វើអន្តរប្រតិបត្តិការទិន្នន័យ និងការទំនាក់ទំនងអេឡិចត្រូនិកក្នុង អយក ត្រូវបានបញ្ចប់ជាស្ថាពរ

**លទ្ធផល ៥.២.១៖** ទ្រង់ទ្រាយស្តង់ដារមូលដ្ឋានសម្រាប់ធ្វើការផ្លាស់ប្តូរទិន្នន័យ និងការទំនាក់ទំនងអេឡិចត្រូនិកក្នុងក្រសួង ត្រូវបានកំណត់ និងដាក់ឲ្យអនុវត្ត

ស្តង់ដារដែលបានកំណត់នៅក្នុងផែនការសកម្មភាព និងស្តង់ដារបំពេញបន្ថែមផ្សេងទៀតដែលចាំបាច់ នឹងត្រូវដាក់ឲ្យអនុវត្ត ។ ជាពិសេស ក្រសួងទាំងមូលនឹងតម្រូវឲ្យប្រើប្រាស់ពុម្ពអក្សរយូនីកូដខ្មែរ ទ្រង់ទ្រាយឯកសារ ODF (Open Document Format) និង ទ្រង់ទ្រាយឯកសារ PDF (Portable Document Format) នៅមុនដំណាច់ឆ្នាំ ២០១០ ។

**អាំងឌីកាទ័រ** ៖ អង្គភាពក្រោមឱវាទក្រសួង អយក សាលារៀន និងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ប្រើប្រាស់ទ្រង់ទ្រាយដែលបានកំណត់នៅមុនដំណាច់ឆ្នាំ ២០១០ និងបញ្ឈប់ការផ្លាស់ប្តូរ និងរក្សាទុកទិន្នន័យ ដែលប្រើប្រាស់ពុម្ពអក្សរចាស់ និងទ្រង់ទ្រាយខុសពីការកំណត់ ។

**គោលបំណង ៥.៣៖** ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ និងមូលដ្ឋានទិន្នន័យទាំងអស់របស់ អយក ត្រូវបានធ្វើឲ្យឯកភាពគ្នា និងដាក់បញ្ចូលគ្នា

**លទ្ធផល ៥.៣.១៖** ប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្មីនឹងត្រូវបង្កើតឡើង ដើម្បីផ្ទុកមូលដ្ឋានទិន្នន័យដែលមានស្រាប់ និងព័ត៌មានទាំងឡាយដែលជាតម្រូវការចាំបាច់របស់ក្រសួង

មូលដ្ឋានទិន្នន័យទាំងអស់របស់ក្រសួង អយក នឹងត្រូវដាក់បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមួយ ដើម្បីកាត់បន្ថយការចំណាយក្នុងការថែរក្សា និងធានានូវលទ្ធភាពតភ្ជាប់គ្នាទៅវិញទៅមក ។ មូលដ្ឋានទិន្នន័យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលមានស្រាប់ (EMIS, HRMIS, FMIS) នឹងត្រូវធ្វើសុខដុមនីយកម្មចូលក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមដែលប្រើប្រាស់កម្មវិធីប្រភពកូដចំហ (Open Source) ដោយមានការគ្រប់គ្រង និងធានាសុវត្ថិភាពជារួម ហើយដែលនឹងមានចំណុចប្រទាក់អ្នកប្រើ (Interfaces) ប្រហាក់ប្រហែលគ្នា ។ ពុម្ពអក្សរយូនីកូដខ្មែរ នឹងត្រូវប្រើក្នុងការអ៊ិនកូដមូលដ្ឋានទិន្នន័យដែលត្រូវធ្វើជាភាសាខ្មែរ ។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្មីនឹងរួមបញ្ចូលការគ្រប់គ្រងព័ត៌មានឧត្តមសិក្សា និងព័ត៌មានអប់រំក្រៅប្រព័ន្ធ។ មូលដ្ឋានទិន្នន័យថ្មីនេះ (ដែលនឹងមានដាក់បញ្ចូលទិន្នន័យសិស្សនិស្សិតទាំងអស់) ក៏នឹងត្រូវកំណត់ និងរៀបចំធ្វើផងដែរ ។

ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នឹងទទួលខុសត្រូវក្នុងការកំណត់យថាប្រភេទ ការរៀបចំ និងការដាក់ឲ្យអនុវត្តមូលដ្ឋានទិន្នន័យថ្មីនេះ។ ដើម្បីអាចរៀបចំកសាងទិន្នន័យទាំងនេះ ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នឹងរៀបចំការសិក្សាវាយតម្លៃមួយដែលផ្តោតលើ ៖

- ការសិក្សាវិភាគលើមូលដ្ឋានទិន្នន័យ និងឧបករណ៍គ្រប់គ្រងព័ត៌មានដែលក្រសួងកំពុងប្រើប្រាស់ ។
- ការសិក្សាវិភាគពីតម្រូវការក្នុងការគ្រប់គ្រងព័ត៌មានអប់រំ (របស់អង្គភាពថ្នាក់កណ្តាល និងតំបន់) ដែលនៅពេលបច្ចុប្បន្ន ព័ត៌មានទាំងនេះ មិនទាន់ត្រូវបានប្រមូល និងផ្តល់ដោយ EMIS ។
- ចំណុចទិន្នន័យ (Data Point) ដែលអនុញ្ញាតឲ្យមានការផ្លាស់ប្តូរទៅវិញទៅមករវាងមូលដ្ឋានទិន្នន័យខុសៗគ្នា និងស្តង់ដារដែលកំពុងប្រើប្រាស់ដោយរាជរដ្ឋាភិបាលកម្ពុជា (លេខកូដរាជធានី-ខេត្ត ។ល។)

មូលដ្ឋានទិន្នន័យថ្មីមួយ (ដែលប្រើប្រាស់បច្ចេកវិទ្យានៃកម្មវិធីប្រភពកូដចំហប្រសិនអាច) នឹងត្រូវកំណត់ និងរៀបចំឡើង ដើម្បីផ្ទុកទិន្នន័យដែលជាតម្រូវការចាំបាច់របស់ក្រសួង ដោយប្រើប្រាស់នូវស្តង់ដារដែលបានកំណត់ ។ មូលដ្ឋានទិន្នន័យទាំងនេះ នឹងរៀបចំសម្រាប់ការបញ្ចូល និងប្រើប្រាស់ទិន្នន័យដោយផ្ទាល់តាមរយៈបណ្តាញផ្ទៃក្នុងរបស់ក្រសួង ឬបណ្តាញអ៊ីនធឺណិត ឬនៅពេលអ្នកប្រើប្រាស់នៅក្រៅបណ្តាញ ។ កម្មវិធីសម្រាប់បញ្ចូលទិន្នន័យនៅពេលអ្នកប្រើប្រាស់នៅក្រៅបណ្តាញ នឹងត្រូវរៀបចំជាផ្នែកមួយរបស់ប្រព័ន្ធ និងជាយន្តការមួយសម្រាប់ការធ្វើសមាហរណកម្មទិន្នន័យដែលបានបញ្ចូលតាមរយៈកម្មវិធីនេះ ឬតាមរយៈប្រព័ន្ធគ្រប់គ្រងសាលារៀន ។

របាយការណ៍ដែលបង្កើតដោយស្វ័យប្រវត្តិចេញពីមូលដ្ឋានទិន្នន័យ នឹងមានបញ្ចូលព័ត៌មានដែលបច្ចុប្បន្នកំពុងត្រូវបានទទួល និងស្នើសុំដោយអង្គភាពថ្នាក់កណ្តាល និងតំបន់ ។

EMIS និងនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងអយក ដែលធ្វើការប្រមូលទិន្នន័យពីប្រព័ន្ធអប់រំ នឹងបញ្ចូលកម្រងសំណួរព័តមានថ្មីដែលចាំបាច់ត្រូវដាក់បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមួយ ។

**អាំងឌីកាទ័រ** ៖ នៅពាក់កណ្តាលឆ្នាំ ២០១១ ប្រព័ន្ធគ្រប់គ្រងព័ត៌មានរួម នឹងដាក់ឲ្យដំណើរការដោយប្រើប្រាស់មូលដ្ឋានទិន្នន័យថ្មី ។

**លទ្ធផល ៥.៣.២៖** នាយកដ្ឋាន មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ខណ្ឌ-ស្រុក ចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្មី

មន្ត្រីនៅតាមនាយកដ្ឋាន នៅតាមមន្ទីរអយក រាជធានី-ខេត្ត និងនៅតាមការិយាល័យអយក ក្រុង-ខណ្ឌ-ស្រុក នឹងបានទទួល ការបណ្តុះបណ្តាលពីការប្រើប្រាស់មូលដ្ឋានទិន្នន័យថ្មី ។ ការបណ្តុះបណ្តាលនឹងផ្តល់ជាបឋមដល់មន្ត្រីនៅតាមមន្ទីរ អយក រាជធានី-ខេត្ត ហើយបន្ទាប់មកនឹងផ្តល់ដល់មន្ត្រីនៅតាមការិយាល័យ អយក ក្រុង-ខណ្ឌ-ស្រុក អំពីរបៀបបញ្ចូល និងប្រើប្រាស់មូលដ្ឋានទិន្នន័យ ។ ការបញ្ចូល និងការប្រើប្រាស់ទិន្នន័យនឹងត្រូវធ្វើវិមជ្ឈការ ប្រសិនបើអាចធ្វើទៅបាន ។

ទិន្នន័យ នឹងត្រូវធ្វើការផ្លាស់ប្ដូរពីការប្រើពុម្ពអក្សរ និងទ្រង់ទ្រាយចាស់ មកប្រើពុម្ពអក្សរយូនីកូដខ្មែរ និងទ្រង់ទ្រាយរបស់មូលដ្ឋានទិន្នន័យថ្មី ។ មន្ត្រីក្រសួងនឹងចាប់ផ្ដើមប្រើប្រាស់មូលដ្ឋានទិន្នន័យថ្មីជំនួសមូលដ្ឋានទិន្នន័យចាស់របស់ប្រព័ន្ធ EMIS HRIMS និង FMIS នៅមុនដំណាច់ឆ្នាំ ២០១១ និងប្រព័ន្ធ NFMIS និង HEIMS នៅមុនដំណាច់ឆ្នាំ ២០១២ ។

**អាំងឌីកាទ័រ** ៖ មន្ត្រីនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង អយក សាលារៀន និងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ប្រើប្រាស់ទ្រង់ទ្រាយដែលបានកំណត់ នៅមុនដំណាច់ឆ្នាំ ២០១១ (សម្រាប់ប្រព័ន្ធ EMIS HRMIS និង FMIS) និងនៅមុនដំណាច់ឆ្នាំ ២០១២ សម្រាប់ប្រព័ន្ធ NFMIS និង HEIMS។ មន្ទីរអប់រំរាជធានី-ខេត្ត និងការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុក នឹងអាចបញ្ចូលទិន្នន័យចូលក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាន ហើយនឹងអាចទាញបញ្ចូលទិន្នន័យរបស់សាលារៀនដែលមានប្រព័ន្ធគ្រប់គ្រងសាលារៀន ។

**គោលបំណង ៥.៤៖** អង្គភាពរដ្ឋបាលទាំងអស់របស់ក្រសួង អយក នឹងអាចផ្លាស់ប្ដូរទិន្នន័យផ្ទៃក្នុងតាមរយៈបណ្ដាញផ្ទៃក្នុង

**លទ្ធផល ៥.៤.១៖** កំណត់ និងដាក់ឲ្យដំណើរការបណ្ដាញកុំព្យូទ័រមូលដ្ឋាន ដែលនឹងបម្រើឲ្យការងាររដ្ឋបាលរបស់ ក្រសួង អយក

បណ្ដាញតភ្ជាប់អង្គភាពរដ្ឋបាលរបស់ក្រសួង នឹងត្រូវរៀបចំបង្កើត ហើយការចំណាយក្នុងការរៀបចំនេះ នឹងដាក់បញ្ចូលក្នុងកញ្ចប់ថវិកាតាមកម្មវិធីរបស់ក្រសួង នៅក្នុងដំណាច់ឆ្នាំ ២០១១ ។ បណ្ដាញនេះនឹងតភ្ជាប់ទៅជាមួយនឹងបណ្ដាញស្រាវជ្រាវសាធារណៈនានា (ដូចជា បណ្ដាញ TEIN) និងដើរតួនាទីជាច្រកចែកចាយការតភ្ជាប់នេះទៅកាន់គ្រឹះស្ថានឧត្តមសិក្សានានា ។

**អាំងឌីកាទ័រ** ៖ ទំនាក់ទំនងអេឡិចត្រូនិករវាងអង្គភាពរដ្ឋបាលទាំងអស់របស់ក្រសួង អយក និងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈតាមរយៈបណ្ដាញផ្ទៃក្នុងអាចដំណើរការទៅបាននៅមុនដំណាច់ឆ្នាំ ២០១១ ។

**គោលបំណង ៥.៥៖** បពស ត្រូវបានប្រើប្រាស់ដើម្បីសម្របសម្រួលការងាររដ្ឋបាលរបស់សាលារៀន និងសាលាគរុកោសល្យដែលមានថាមពលតអគ្គិសនីប្រើប្រាស់

**លទ្ធផល ៥.៥.១៖** សាលាគរុកោសល្យ និងសាលាមធ្យមសិក្សា ប្រើប្រាស់កម្មវិធីគ្រប់គ្រងព័ត៌មានដើម្បីសម្រួលដល់ការងាររដ្ឋបាល

សាលាគរុកោសល្យទាំងអស់ និងវិទ្យាល័យចំនួន ១២០ នឹងប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីចុះឈ្មោះ និងគ្រប់គ្រងគរុសិស្ស និងសិស្ស សកម្មភាព និងកញ្ចប់ថវិកា ហើយបញ្ចូលទិន្នន័យជាប្រចាំតាមទ្រង់ទ្រាយដែលអាចបញ្ចូលក្នុង EMIS ។

**អាំងឌីកាទ័រ** ៖ វិទ្យាល័យចំនួន ១២០ និងសាលាគរុកោសល្យទាំងអស់ដែលមានថាមពលអគ្គិសនីប្រើប្រាស់សម្រាប់គ្រប់គ្រងរដ្ឋបាល ដោយប្រើកុំព្យូទ័រនៅមុនដំណាច់ឆ្នាំ ២០១៣ ។

**គោលបំណង ៥.៦៖** ការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុកប្រើប្រាស់ បពស ដើម្បីសម្រួលដល់ការងាររដ្ឋបាល

**លទ្ធផល ៥.៦.១៖** អគ្គិសនីភាវូបនីយកម្មដល់ការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុកដែលមិនទាន់មានថាមពលអគ្គិសនីប្រើប្រាស់

ការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុក ដែលមិនទាន់មានថាមពលអគ្គិសនីប្រើប្រាស់ នឹងមានប្រភពថាមពលអគ្គិសនីតាមប្រភពផ្សេងៗ ប្រើប្រាស់ នៅមុនពាក់កណ្តាលឆ្នាំ ២០១១ ។

**អាំងឌីកាទ័រ** ៖ ការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុកទាំងអស់ មានថាមពលអគ្គិសនីគ្រប់គ្រាន់ល្មមសម្រាប់ដំណើរការកុំព្យូទ័រចំនួន ២ គ្រឿង នៅមុនពាក់កណ្តាលឆ្នាំ ២០១១ ។

**លទ្ធផល ៥.៦.២៖** ផ្តល់សម្ភារ បពស និងបណ្តុះបណ្តាលបុគ្គលការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុកទាំង ១៩៣

ការិយាល័យអប់រំ ក្រុង-ខណ្ឌ-ស្រុកទាំង ១៩៣ នឹងត្រូវបំពាក់កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព និងសម្ភារផ្សេងទៀត នៅមុនដំណាច់ឆ្នាំ ២០១១ ហើយការបណ្តុះបណ្តាល បពស នឹងផ្តល់ដល់បុគ្គលិករបស់ការិយាល័យទាំងនេះ ។

**អាំងឌីកាទ័រ** ៖ ការិយាល័យអប់រំក្រុង-ខណ្ឌ-ស្រុកទាំងអស់ ប្រើប្រាស់កុំព្យូទ័រដើម្បីជួយដល់ការងារប្រចាំថ្ងៃ ការងារគ្រប់គ្រងទិន្នន័យអប់រំ និងដើម្បីបញ្ចូលទិន្នន័យចូលក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានរួម នៅមុនដំណាច់ឆ្នាំ ២០១១ ។

**គោលបំណង ៥.៧៖** ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នឹងត្រូវពង្រឹងសមត្ថភាព ដើម្បីជួយសម្របសម្រួលសកម្មភាព បពស របស់ក្រសួង

**លទ្ធផល ៥.៧.១៖** ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ សម្របសម្រួលសកម្មភាព បពស ទាំងអស់របស់ក្រសួង

ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នឹងមានធនធានគ្រប់គ្រាន់ក្នុងការផ្តល់ការគាំទ្រដល់ដំណើរការរដ្ឋបាល និងបច្ចេកវិទ្យាអប់រំផ្ទៃក្នុងរបស់ក្រសួង និងធានានូវប្រសិទ្ធភាព និរន្តរភាព និងចិរភាពនៃដំណើរការទាំងនេះ ។ លំនឹងធនធានក្នុង និងក្រៅ សម្រាប់តម្រូវការបច្ចេកវិទ្យានឹងត្រូវបំពេញ ។ ធនធានចាំបាច់ដើម្បីដឹកនាំ និងគ្រប់គ្រងដំណើរការទាំងនេះ នឹងផ្តល់ឲ្យការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នៅមុនដំណាច់ឆ្នាំ ២០១០ ។

**អាំងឌីកាទ័រ** ៖ ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ មានរចនាសម្ព័ន្ធសមស្រប និងមានធនធានគ្រប់គ្រាន់ ដើម្បីធានាថាផែនការគោលស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ អាចអនុវត្តទៅបាន នៅមុនដំណាច់ឆ្នាំ ២០១០ ។

**លទ្ធផល ៥.៧.២៖** ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសដែលចាំបាច់សម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្មី ត្រូវបានកសាង និងដាក់ឲ្យដំណើរការ

ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នឹងសម្របសម្រួលការងាររៀបចំបង្កើតកម្មវិធីប្រើនៅលើបណ្តាញ ដែលនឹងប្រើធ្វើជាមជ្ឈមណ្ឌលធនធានអប់រំសម្រាប់ការបណ្តុះបណ្តាលគ្រូ និងការអប់រំថ្នាក់ឧត្តមសិក្សា ។

**អាំងឌីកាទ័រ** ៖ កម្មវិធីនេះ នឹងត្រូវបានរៀបចំ និងដាក់ឲ្យប្រើប្រាស់នៅមុនពាក់កណ្ដាលឆ្នាំ ២០១១ ។

**គោលបំណង ៥.៨៖** ការចំណាយវិនិយោគ និងការចំណាយនិរន្តរក្នុងការអនុវត្ត បពស ក្នុងវិស័យអប់រំ ត្រូវចែករំលែកដោយអ្នកពាក់ព័ន្ធទាំងអស់

**លទ្ធផល ៥.៨.១៖** កម្មវិធីភាពជាដៃគូត្រូវបានបង្កើត

នៅមុនដំណាច់ឆ្នាំ ២០១១ កម្មវិធីភាពជាដៃគូមួយនឹងត្រូវបង្កើត ដើម្បីប្រមូលថវិកា និងការគាំទ្រពីអ្នកពាក់ព័ន្ធថ្នាក់ជាតិ និងអន្តរជាតិ ដែលមានដូចជាអ្នកផ្ដល់ជំនួយ វិស័យឯកជន សហគមន៍មូលដ្ឋាន សមាគមវិជ្ជាជីវៈ និងបុគ្គលដែលអាចជួយចែករំលែកការចេញចំណាយក្នុងការអនុវត្ត បពស ក្នុងវិស័យអប់រំ។ ដៃគូអភិវឌ្ឍន៍ថ្មីដែលគាំទ្រគោលដៅ និងយថាប្រភេទបច្ចេកទេសនៃផែនការគោលនេះ នឹងត្រូវបានទទួលការស្វាគមន៍ ។

**អាំងឌីកាទ័រ** ៖ ភាពជាដៃគូដែលកំពុងមានជាមួយក្រុមហ៊ុន មិត្តហ្វូន និងក្រុមហ៊ុន Intel កាន់តែមានការរីកចម្រើន ហើយនឹងមានការកសាងភាពជាដៃគូថ្មីបន្ថែមទៀត នៅក្នុងអំឡុងពេលចុងក្រោយនៃផែនការគោលនេះ (នៅមុនដំណាច់ឆ្នាំ ២០១៣) ។

# ៦. ធាតុសំខាន់ៗសម្រាប់ភាពជោគជ័យនៃការអនុវត្តផែនការគោល

## ៦.១. កម្មវិធីសិក្សា

### ៦.១.១. បំណិនវិជ្ជាជីវៈផ្អែកលើ បពស សម្រាប់សិស្សសាលា

**វគ្គសិក្សាដែលត្រូវបង្កើត**

វគ្គសិក្សាបំណិនវិជ្ជាជីវៈផ្អែកលើ បពស នឹងត្រូវរៀបចំឡើងសម្រាប់សិស្សថ្នាក់ទី ១០ (ជាវគ្គសិក្សាបំណិនជីវិត) និងសិស្សថ្នាក់ ទី ១១ និងថ្នាក់ទី ១២ ដែលជាផ្នែកមួយនៃកម្មវិធីអប់រំវិជ្ជាជីវៈជម្រើស ។ សមត្ថភាពដែលបានពីការរៀន (ឬ ហៅថា "ជំនាញសម្រាប់សតវត្សទី ២១") នឹងមានបញ្ចូលការសិក្សាស្វែងយល់ពី និងការទំនាក់ទំនងនៅទីកន្លែងធ្វើការដោយមានការបណ្ដុះបណ្ដាលពីជំនាញសម្រាប់កិច្ចការរដ្ឋបាល (រៀបចំលិខិត ឯកសារ បញ្ជីទំនាក់ទំនង ស្វែងរកព័ត៌មាន និងផែនការថវិកា) ។ ចំណែកផ្នែកបច្ចេកទេសវិញ សិស្សនឹងសិក្សាពីរបៀបប្រើប្រាស់កម្មវិធីកុំព្យូទ័រភាសាខ្មែរដែលរួមមានកម្មវិធីវាយអត្ថបទ កម្មវិធីរៀបចំសៀវភៅបញ្ជី កម្មវិធីធ្វើបទបង្ហាញ កម្មវិធីផ្ញើសារអេឡិចត្រូនិក និងកម្មវិធីរុករកអ៊ីនធឺណិត ។

វគ្គសិក្សាកម្មវិធីអប់រំវិជ្ជាជីវៈជម្រើសទាំងនេះ នឹងដាក់បញ្ចូលក្នុងកម្មវិធីសិក្សា និងចាប់ផ្ដើមសាកល្បងនៅក្នុងឆ្នាំសិក្សា ២០១០-២០១១ ។ សម្រាប់សិស្សថ្នាក់ទី ១០ មុខវិជ្ជាសិក្សានេះនៅតែជាផ្នែកមួយនៃកម្មវិធីបំណិនជីវិត ប៉ុន្តែសាលារៀននឹងត្រូវបានអនុញ្ញាតឲ្យគ្រូបង្រៀនយកម៉ោងបង្រៀនមុខវិជ្ជា បពស ដូចមុខវិជ្ជាសិក្សាដទៃទៀតដែរ ។

**គ្រូបង្រៀនបំណិនវិជ្ជាជីវៈផ្អែកលើ បពស**

ចាប់ពីឆ្នាំសិក្សា ២០០៩ - ២០១០ វិទ្យាស្ថានជាតិអប់រំ នឹងបណ្ដុះបណ្ដាលគ្រូឯកទេសគណិតវិទ្យា រូបវិទ្យា ភាសា-អង់គ្លេស សេដ្ឋកិច្ច និងកសិកម្ម ឲ្យមានជំនាញបង្រៀន បពស ជាជំនាញឯកទេសទី២។ ជាលទ្ធផល គ្រូថ្មីចំនួន ៤០ ភាគរយ នឹងមានជំនាញបង្រៀន បពស នៅតាមសាលារៀន ។

### ៦.១.២. អក្ខរកម្ម បពស សម្រាប់គ្រូបង្រៀន

គរុសិស្សនៅតាមសាលាគរុកោសល្យទាំងអស់ដែលមានបំពាក់ម៉ាស៊ីនកុំព្យូទ័រ នឹងទទួលបានការបណ្ដុះបណ្ដាលបំណិនវិជ្ជាជីវៈផ្អែកលើ បពស សម្រាប់គ្រូបង្រៀន សម្រាប់កិច្ចការអប់រំ និងកិច្ចការរដ្ឋបាល ។ កម្មវិធីសិក្សាថ្មី នឹងត្រូវបានរៀបចំសម្រាប់សាលាគរុកោសល្យទាំងអស់ក្នុងឆ្នាំសិក្សា ២០០៩-២០១០ ។

## ៦.២. សម្ភារបរិក្ខារ

### ៦.២.១. សម្ភារៈបរិក្ខារសម្រាប់សាលារៀន និងសាលាគរុកោសល្យ

**កុំព្យូទ័រ**

ក្រសួងនឹងកំណត់ពីយថាប្រភេទសម្រាប់បន្ទប់សិក្សាកុំព្យូទ័រនៅតាមសាលារៀន ។ កុំព្យូទ័រដែលត្រូវបំពាក់នៅតាមសាលារៀនតាមផែនការនេះ ត្រូវតែជាប្រភេទកុំព្យូទ័រលើតុ (Desktop) ប្រើថាមពលអគ្គិសនីតិច (ក្រោម ៧០ វ៉ាត់ គិតទាំងម៉ូនីទ័រផង) ត្រូវការការថែទាំតិចតួច និងមានអេក្រង់ធំល្មមអាចមើលឃើញអត្ថបទជាភាសាខ្មែរបានច្បាស់ (យ៉ាងតិច

១៦ អ៊ិន្ឈ៍) ។ បន្ទប់សិក្សាកុំព្យូទ័រ ត្រូវមានកុំព្យូទ័រយ៉ាងតិចចំនួន ២៦ គ្រឿង ប្រសិនបើអាច និងអាចទទួលសិស្សឲ្យចូលសិក្សាពី ៤០ ទៅ ៦០ នាក់។ ម៉ាស៊ីនកុំព្យូទ័រ នឹងត្រូវតភ្ជាប់គ្នាជាបណ្ដាញ ។ ការចំណាយក្នុងការថែទាំត្រូវតែកាត់បន្ថយឲ្យបានជាអប្បបរមា ហើយលទ្ធកម្មកុំព្យូទ័រត្រូវតែមានភ្ជាប់នូវកិច្ចសន្យាថែទាំរយៈពេលបីឆ្នាំ ។

សាលារៀនដែលមានកុំព្យូទ័រសម្រាប់សិស្ស ក៏ត្រូវមានកុំព្យូទ័រសម្រាប់គ្រូផងដែរ ដើម្បីឲ្យលោកគ្រូអ្នកគ្រូ អាចប្រើប្រាស់សម្រាប់កិច្ចការរដ្ឋបាល និងរៀបចំសម្ភារឧបទេស ។ ផលធៀបរវាងកុំព្យូទ័រ និងគ្រូបង្រៀនត្រូវនៅចន្លោះពី ១:៥ និង ១:១០ ។

## កម្មវិធីកុំព្យូទ័រ

កម្មវិធីកុំព្យូទ័រទំនើបៗជាភាសាខ្មែរដែលត្រូវបានកែសម្រួលឲ្យស្របតាមវប្បធម៌របស់ខ្មែរ ត្រូវបានដាក់ឲ្យប្រើប្រាស់រួចហើយ ហើយក៏មានឯកសារបណ្ដុះបណ្ដាលដែលបានអនុម័តដោយក្រសួងសម្រាប់កម្មវិធីកុំព្យូទ័រទាំងនេះ ។ ក្រសួងនឹងធានាថា៖

- មានតែកម្មវិធីកុំព្យូទ័រដែលមានជាភាសាខ្មែរ ១០០ ភាគរយ និងដែលត្រូវបានកែសម្រួលឲ្យស្របតាមវប្បធម៌ខ្មែរ និងការតម្រូវរបស់ក្រសួងប៉ុណ្ណោះ ទើបអាចទទួលបានការអនុម័តពីក្រសួង និងអាចដាក់ឲ្យប្រើប្រាស់នៅតាមសាលារៀន និងសាកលវិទ្យាល័យ ដើម្បីបង្រៀនពី បពស[១] ។
- មានតែកម្មវិធីដែលមានសៀវភៅណែនាំដែលអនុម័តដោយក្រសួងប៉ុណ្ណោះទើបអាចយកមកបង្រៀន ។ សៀវភៅណែនាំ ត្រូវតែគោរពតាមកម្មវិធីសិក្សាដែលមានស្រាប់ ដើម្បីធានាថាសិស្សនឹងទទួលបានបំណិនវិជ្ជាជីវៈ មិនមែនតែជំនាញបច្ចេកទេសនោះទេ ។
- ក្រសួងនឹងរក្សាកម្មសិទ្ធិ និងសិទ្ធិអ្នកនិពន្ធគ្រប់យ៉ាងលើសម្ភារឧបទេស និងកម្មវិធីដែលក្រសួងបានផលិតក្នុងបរិបទនៃផែនការគោលនេះ ។ ក្រសួងនឹងផ្ដល់អាជ្ញាប័ណ្ណឲ្យដល់តតិយជន ដោយប្រើអាជ្ញាប័ណ្ណសមស្រប ដើម្បីឲ្យតតិយជនអាចប្រើប្រាស់ កែប្រែ ចែកចាយ ឬកែលម្អសម្ភារទាំងនេះ ឬធ្វើបដិរូបកម្ម ឬផលិតសម្ភារថ្មីចេញពី

១. កម្មវិធីកុំព្យូទ័រដែលនឹងត្រូវចែកចាយ ត្រូវតែអាចធ្វើការពិនិត្យអក្ខរាវិរុទ្ធពាក្យខ្មែរ តំរៀបលំដាប់ពាក្យតាមលំដាប់ស្ដង់ដារតួអក្សរខ្មែរ និងអាចដាក់លេខ និងថ្ងៃខែតាមទម្រង់ខ្មែរ (ស្របតាមទម្រង់ដែលបង្រៀនក្នុងមុខវិជ្ជាគណិតវិទ្យានៅតាមសាលារៀន)។ កម្មវិធីកុំព្យូទ័រដែលត្រូវបង្រៀន ត្រូវតែអាចប្រើពុម្ពអក្សរយូនីកូដបានត្រឹមត្រូវ និងអាចបង្កើតទ្រង់ទ្រាយដែលក្រសួងចាត់ទុកជាទ្រង់ទ្រាយស្ដង់ដារ (ODF, PDF)។ កម្មវិធីកុំព្យូទ័រដែលអាចបង្រៀនក្នុងប្រព័ន្ធអប់រំ ត្រូវតែអាចរកបានដោយស្របច្បាប់ ហើយផលិតករកម្មវិធីត្រូវតែបង្ហាញថាកម្មវិធីរបស់ខ្លួននឹងមិនងាយរងការវាយប្រហារពីមេរោគ ឬកម្មវិធីចង្រៃផ្សេងៗឡើយ។ កម្មវិធីត្រូវតែមានល្បឿនដំណើរការដែលអាចទទួលយកបាននៅលើម៉ាស៊ីនកុំព្យូទ័រប្រើថាមពលអគ្គិសនីតិចដែលកំណត់ដោយផែនការគោលនេះ។ នៅពេលជ្រើសរើសកម្មវិធីដែលបំពេញលក្ខខណ្ឌតម្រូវនេះ តម្លៃលក់រាយរបស់កម្មវិធី នឹងក្លាយជាកត្តាសំខាន់ក្នុងការសម្រេចជ្រើសរើសកម្មវិធីដែលដាក់ឲ្យប្រើនៅតាមសាលារៀន។ សិស្ស នឹងរៀនសម្គាល់ពីកម្មវិធីដែលពួកគេអាចប្រើប្រាស់ដោយឥតគិតថ្លៃ និងអាចចែករំលែកជាមួយអ្នកដទៃ (ករណីកម្មវិធីកូដបើកចំហ និងឥតគិតថ្លៃ) និងកម្មវិធីដែលត្រូវទិញអាជ្ញាប័ណ្ណប្រើប្រាស់ និងដែលមិនអាចចែករំលែក ឬលក់ឲ្យអ្នកដទៃ ឬផ្ទេរទៅម៉ាស៊ីនកុំព្យូទ័រផ្សេងទៀត។ សិស្សនឹងត្រូវហាមឃាត់មិនឲ្យប្រើប្រាស់កម្មវិធីគិតថ្លៃដែលគ្មានអាជ្ញាប័ណ្ណប្រើប្រាស់ត្រឹមត្រូវ។

សម្ភារទាំងនេះ ។ ការធ្វើបែបនេះ នឹងជួយធ្វើឲ្យសម្ភារដែលនឹងប្រើប្រាស់ដោយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស មានគុណភាពកាន់តែប្រសើរឡើង[២] ។

## ការតភ្ជាប់បណ្ដាញ

នៅតាមសាលាគរុកោសល្យ និងសាលារៀនទាំងអស់ កុំព្យូទ័រដែលប្រើសម្រាប់ការងារអប់រំ និងកិច្ចការរដ្ឋបាល នឹងមានភ្ជាប់សេវាអ៊ីនធឺណិតប្រើប្រាស់គ្រប់កុំព្យូទ័រ ។

## ៦.២.២. សម្ភារបរិក្ខារសម្រាប់ក្រសួង

## កម្មវិធីកុំព្យូទ័រសម្រាប់ម៉ាស៊ីនបម្រើ និងសម្រាប់អ្នកប្រើប្រាស់

រដ្ឋបាលរបស់ក្រសួងក៏នឹងត្រូវប្រើប្រាស់កម្មវិធីជាភាសាខ្មែរ ។ លទ្ធកម្មកម្មវិធីកុំព្យូទ័រសម្រាប់ការិយាល័យរបស់ក្រសួង ត្រូវអនុវត្តតាមវិធានដែលកំណត់ចំពោះការធ្វើលទ្ធកម្មកម្មវិធីកុំព្យូទ័រសម្រាប់សាលារៀន ដើម្បីជួយឲ្យមន្ត្រីក្រសួង អយក ទាំងអស់មានភាពងាយស្រួលក្នុងការប្រើប្រាស់កម្មវិធីកុំព្យូទ័រមូលដ្ឋាន។ ក្រសួងនឹងព្យាយាមប្រើប្រាស់កម្មវិធីកូដចំហប្រសិនបើអាច សម្រាប់ការងារកសាងមូលដ្ឋានទិន្នន័យរបស់ក្រសួង និងការងារគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង ។

## ស្តង់ដារ

ការប្រើស្តង់ដារ គឺជាគន្លឹះក្នុងការពង្រីកការប្រើប្រាស់ បពស ។ ស្តង់ដារជាតិ និងអន្តរជាតិនឹងត្រូវយកមកប្រើក្នុងការអនុវត្តផែនការគោលនេះ ដែលមានដូចជា ៖ (ក) ពុម្ពអក្សរយូនីកូដស្តង់ដារ (ISO 10646) (ខ) ក្ដារចុចយូនីកូដស្តង់ដាររបស់ NiDA (កំណែលើកទី 1) ដែលកំណត់ដោយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា នៅឆ្នាំ ២០០៥ ឬក្ដារចុចយូនីកូដស្តង់ដារដែលនឹងចេញនៅពេលអនាគត ប៉ុន្តែលុះត្រាតែក្ដារចុចយូនីកូដស្តង់ដារថ្មីនោះ យកលំនាំតាមក្ដារចុចយូនីកូដស្តង់ដារចាស់ទាំងស្រុង ។ (គ) Open Document Format (ODF) ស្តង់ដារ (ISO 26300:2006) នឹងត្រូវប្រើសម្រាប់ឯកសារការិយាល័យ ដែលអាចនឹងត្រូវកែសម្រួលបន្ថែម ឬដែលមាតិកាព័ត៌មានរបស់វាអាចនឹងមានប្រយោជន៍សម្រាប់ឯកសារផ្សេងទៀត ។ (ឃ) Portable Document Format (PDF) នឹងត្រូវប្រើសម្រាប់ឯកសារដែលលែងត្រូវការកែសម្រួល ។ លើសពីនេះ ក្រសួងនឹងកំណត់ស្តង់ដារសម្រាប់បន្ទប់សិក្សាកុំព្យូទ័រ និងការបំពាក់កុំព្យូទ័រនៅតាមសាលារៀន ។

២. កម្មវិធីកុំព្យូទ័រ នឹងផ្តល់អាជ្ញាប័ណ្ណតាមរយៈអាជ្ញាប័ណ្ណ GNU General Public License (GPL) ឬអាជ្ញាប័ណ្ណ GNU Lesser Public License (LGPL)។ មាតិកាព័ត៌មាន នឹងត្រូវផ្តល់អាជ្ញាប័ណ្ណតាមរយៈអាជ្ញាប័ណ្ណ Creative Common Attribution License ដែលអនុញ្ញាតឲ្យប្រើប្រាស់សម្ភារសម្រាប់គោលដៅពាណិជ្ជកម្ម (ដើម្បីលើកទឹកចិត្តឲ្យមានការចូលរួមអភិវឌ្ឍសម្ភារពីវិស័យឯកជនដើម្បីឲ្យសម្ភារមានគុណភាពកាន់តែប្រសើរឡើង និងដើម្បីឲ្យមានការប្រកួតប្រជែងតម្លៃបោះពុម្ព) និងអនុញ្ញាតឲ្យមានការកែប្រែ ប៉ុន្តែតម្រូវឲ្យមានការទទួលស្គាល់ថាសម្ភារច្បាប់ដើមជារបស់ក្រសួង។

## ការតភ្ជាប់បណ្តាញ

អង្គភាពថ្នាក់កណ្តាលរបស់ក្រសួងនៅរាជធានីភ្នំពេញ នឹងតភ្ជាប់គ្នាតាមរយៈបណ្តាញក្នុងតំបន់ ឬបណ្តាញឯកជននិម្មិត (VPN) តាមរយៈប្រព័ន្ធអ៊ីនធឺណិត និងអាចចែករំលែកព័ត៌មានគ្នាទៅវិញទៅមក ។ នៅថ្ងៃអនាគត បណ្តាញនេះ នឹងភ្ជាប់ការិយាល័យទាំងអស់របស់ក្រសួង និងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទាំងអស់ ។ ក្រសួង ឬរាជរដ្ឋាភិបាល នឹងព្យាយាមធ្វើជាម្ចាស់បណ្តាញនេះដោយខ្លួនឯង ដើម្បីចៀសវាងការចំណាយនិរន្តរក្នុងការតភ្ជាប់ ដែលនឹងត្រូវកើនឡើង ប្រសិនបើមានការតភ្ជាប់កាន់តែច្រើនឡើង ។ បណ្តាញនេះ នឹងបន្តតភ្ជាប់វិទ្យាល័យ និងសាលាគរុកោសល្យ ឲ្យបានច្រើនតាមលទ្ធភាពដែលធ្វើទៅបាន ។ បណ្តាញរដ្ឋបាលរបស់ក្រសួង នឹងភ្ជាប់ទៅកាន់បណ្តាញសិក្សាស្រាវជ្រាវ បណ្តាញរបស់រដ្ឋាភិបាល និងបណ្តាញអន្តរជាតិនានា ដូចជាបណ្តាញសិក្សាស្រាវជ្រាវ TEIN3 ជាដើម ។

## ៦.៣. ធនធានមនុស្ស

### ៦.៣.១. តួនាទីពាក់ព័ន្ធនឹង បពស នៅតាមសាលារៀន

នៅតាមសាលារៀន គ្រូបង្រៀន បពស គឺជាបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលច្រើនជាងគេបំផុតអំពីកុំព្យូទ័រ ។ ពួកគាត់នឹងដើរតួនាទីជាអ្នកផ្តល់ការគាំទ្រដល់បុគ្គលិកដទៃទៀត ប្រសិនបើចាំបាច់ ។ ក្រៅពីតួនាទីជាអ្នកបណ្តុះបណ្តាលសិស្ស ពួកគាត់នឹងដើរតួនាទីជាអ្នកបណ្តុះបណ្តាលមិត្តរួមការងារ និងមានតួនាទីជាអ្នកគាំទ្រដល់ដំណើរការស្វ័យប្រវត្តិកម្មរដ្ឋបាលរបស់សាលារៀន ។ ក្រៅពីចំណេះដឹងចាំបាច់សម្រាប់ការបង្រៀនមុខវិជ្ជា បពស គ្រូបង្រៀន បពស ក៏ត្រូវទទួលការបណ្តុះបណ្តាលអំពីចំណេះដឹងមូលដ្ឋានក្នុងការថែទាំកុំព្យូទ័រ ដើម្បីឲ្យពួកគាត់អាចផ្តល់ការថែទាំបឋមដល់កុំព្យូទ័រនៅតាមសាលារៀន ។ គ្រូបង្រៀន បពស នឹងបង្កើនតួនាទីបន្តិចម្តងៗក្នុងការចាប់ផ្តើមតួនាទីជាអ្នកបង្រៀនអំពីទំនាក់ទំនង ការមានទំនុកចិត្តលើខ្លួនឯង និងបំណិនរស់នៅក្នុងសង្គម ដែលជាផ្នែកមួយនៃវគ្គសិក្សា បពស ដែលផ្តោតទៅលើការបណ្តុះបណ្តាលបច្ចេកទេសឲ្យសិស្សចេះរួមសហការធ្វើការងារជាក្រុម ។

ក្រសួងក៏នឹងយកចិត្តទុកដាក់ចំពោះតួនាទីរបស់នាយកសាលាផងដែរ ដោយក្រសួងនឹងបណ្តុះបណ្តាលពួកគាត់ពីរបៀបផ្តល់ការគាំទ្រដល់ការបង្រៀន បពស នៅតាមសាលារៀន ។

### ៦.៣.២. តួនាទីពាក់ព័ន្ធនឹង បពស នៅតាមសាលាគរុកោសល្យ

នៅតាមសាលាគរុកោសល្យនីមួយៗ នឹងមានគ្រូបង្គោល បពស យ៉ាងតិចចំនួនពីររូប ដែលមានចំណេះដឹងបង្រៀន បពស និងចំណេះដឹងមូលដ្ឋានក្នុងការថែទាំម៉ាស៊ីនកុំព្យូទ័រ និងក្នុងការផ្តល់ការគាំទ្រដល់ដំណើរការស្វ័យប្រវត្តិកម្មរដ្ឋបាលរបស់សាលាគរុកោសល្យ ។ គ្រូបង្គោល បពស នឹងបង្កើនតួនាទីបន្តិចម្តងៗក្នុងការចាប់ផ្តើមតួនាទីជាអ្នកបង្រៀនអំពីទំនាក់ទំនង ការមានទំនុកចិត្តលើខ្លួនឯង និងជំនាញរស់នៅក្នុងសង្គម ដែលជាផ្នែកមួយនៃវគ្គសិក្សា បពស ដោយប្រើប្រាស់វិធីសាស្ត្របង្រៀន តាមបែបសិស្សមជ្ឈមណ្ឌល ក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់គរុសិស្ស ។

គ្រូបង្គោល បពស នៅវិទ្យាស្ថានជាតិអប់រំ គឺជាអ្នកបណ្តុះបណ្តាល បពស ដែលមានឯកទេសបំផុតរបស់ក្រសួង ។ ពួកគាត់នឹងបណ្តុះបណ្តាលគរុសិស្ស បពស គ្រូបង្គោល បពស សម្រាប់សាលាគរុកោសល្យ និងគ្រូឧបទេសទូទាំងប្រទេស នៅវិទ្យាស្ថានជាតិអប់រំ ។

ក្រសួងក៏នឹងយកចិត្តទុកដាក់ចំពោះតួនាទីរបស់នាយកសាលាគរុកោសល្យផងដែរ ដោយក្រសួងនឹងបណ្តុះបណ្តាល ពួកគាត់អំពីរបៀបផ្តល់ការគាំទ្រដល់ការបង្រៀន បពស នៅតាមសាលាគរុកោសល្យ ។

### ៦.៣.៣. តួនាទីពាក់ព័ន្ធនឹង បពស នៅក្រសួង អយក និងមន្ទីរ អយក រាជធានី-ខេត្ត

ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នៃនាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន មានតួនាទីសម្របសម្រួលសកម្មភាព បពស ទាំងអស់របស់ក្រសួង ។ ជាផ្នែកមួយនៃផែនការគោលនេះ ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ នឹងសម្របសម្រួលឲ្យមានកំណើននៃការប្រើប្រាស់ បពស នៅក្នុងក្រសួង តាមរយៈការ (ក) ពង្រឹងការប្រើប្រាស់ស្តង់ដារ និងជំរុញឲ្យមានការទំនាក់ទំនង (ខ) ផ្តល់ការពិគ្រោះ បពស ដល់អង្គភាពនានា (គ) សម្របសម្រួលសកម្មភាព និងការផ្តល់ជំនួយរបស់ដៃគូអភិវឌ្ឍន៍របស់ អយក និង (ឃ) ធានាថាខ្លឹមសាររបស់ផែនការគោលត្រូវបានអនុវត្តតាមការគ្រោងទុក ។

នៅដំណាក់កាលទី ២ មន្ទីរ អយក រាជធានី-ខេត្ត នឹងមានការិយាល័យ បពស ទទួលខុសត្រូវក្នុងការធានាថា ប្រតិបត្តិការ និងការបណ្តុះបណ្តាល បពស នៅក្នុងរាជធានី-ខេត្តនិមួយៗ ប្រព្រឹត្តទៅតាមការគ្រោងទុក ។

## ៦.៤. ការអភិវឌ្ឍ បពស នាពេលអនាគត និងការគ្រប់គ្រងកម្មវិធី បពស

កង្វះខាតកុំព្យូទ័រ ហេដ្ឋារចនាសម្ព័ន្ធ និងការទំនាក់ទំនងនៅតាមរាជធានី-ខេត្តមួយចំនួន ជាឧបសគ្គក្នុងការប្រើប្រាស់កុំព្យូទ័រ ក្នុងការបង្ហាត់បង្រៀនមុខវិជ្ជាផ្សេងទៀត ក្រៅពីមុខវិជ្ជា បពស ព្រោះថាហេដ្ឋារចនាសម្ព័ន្ធដែលកំពុងផ្តល់ឲ្យនៅមិនទាន់គ្រប់គ្រាន់សម្រាប់ផ្តល់ការបណ្តុះបណ្តាល បពស ដល់សិស្ស និងលោកគ្រូអ្នកគ្រូ សម្រាប់ប្រើប្រាស់ធ្វើកិច្ចការរដ្ឋបាលឡើយ ។ ធនធានដែលត្រូវការដើម្បីអាចប្រើប្រាស់កុំព្យូទ័រសម្រាប់បង្ហាត់បង្រៀនមុខវិជ្ជាផ្សេងទៀត មានទំហំលើសពីការចំណាយដែលផែនការគោលនេះមានលទ្ធភាពផ្តល់ ។ ម៉្យាងវិញទៀត ការផលិតសម្ភារបង្រៀនតាមកុំព្យូទ័រជាភាសាខ្មែរ ត្រូវចំណាយពេលយូរដែលត្រូវតែចាប់ផ្តើមនៅពេលនេះ ប៉ុន្តែនឹងមិនផ្តល់ផលប៉ះពាល់ច្រើននៅអំឡុងពេលនៃផែនការគោលនេះ ។

ផ្ទុយមកវិញ វីដេអូបណ្តុះបណ្តាលជាបច្ចេកវិទ្យាមួយដែលអាចប្រើប្រាស់បានទូលំទូលាយ ព្រោះថាសូម្បីតែភូមិដាច់ស្រយាលដែលគ្មានភ្លើងអគ្គិសនីប្រើប្រាស់ ក៏អាចនឹងមានទូរទស្សន៍ ឧបករណ៍ចាក់វីដេអូ និងអាគុយ ១២ វ៉ុល ប្រើប្រាស់សម្រាប់ការកម្សាន្តផងដែរ ។

វីដេអូ ជាឧបករណ៍បណ្តុះបណ្តាលដ៏ល្អមួយ ព្រោះវាប្រើប្រាស់វិធីសាស្ត្របណ្តុះបណ្តាលដែលមានប្រសិទ្ធភាពបំផុត ៖ គ្រាប់តាមសកម្មភាពបង្រៀន-រៀនដែលបង្ហាញនៅក្នុងវីដេអូ ។ ការបណ្តុះបណ្តាលទ្រឹស្តីនៅក្នុងថ្នាក់រួចហើយចុះអនុវត្តជាក់ស្តែងដោយមិនបានឃើញសកម្មភាពអនុវត្តជាគំរូ ជាការលំបាកមួយចំពោះគរុសិស្ស ជាពិសេសបើយើងគិតពីកម្រិត

នៃការបណ្តុះបណ្តាលរបស់គរុសិស្សភាគច្រើន ។ ប្រសិនបើគរុសិស្សបានឃើញពីរបៀបបង្រៀនល្អៗ របស់គ្រូបង្រៀនដែលមានបទពិសោធន៍ សិក្សាវិភាគពីចំណុចល្អ ហើយធ្វើត្រាប់តាមការបង្រៀននោះ គរុសិស្សនឹងអាចយល់ពីរបៀបបង្រៀនបានល្អប្រសើរជាងមុន ហើយនឹងធ្វើឲ្យគរុសិស្សមើលឃើញការបង្រៀនលែងជាការលំបាកដូចការធ្លាប់គិតរបស់ពួកគេ ។

វីដេអូបណ្តុះបណ្តាល មិនមែនផលិតឡើងដើម្បីជំនួសគ្រូឧទេសនោះទេ ប៉ុន្តែដើម្បីផ្តល់ឲ្យពួកគាត់នូវឧបករណ៍បន្ថែមក្នុងការបណ្តុះបណ្តាលគរុសិស្ស ។ វីដេអូបណ្តុះបណ្តាល ក៏អាចប្រើប្រាស់ក្នុងការធ្វើវិក្រឹតការគ្រូផងដែរ ដូចជានៅក្នុងការប្រជុំកម្រងសាលារៀនប្រចាំសប្តាហ៍ នៅកន្លែងដែលមានឧបករណ៍បញ្ចាំងវីដេអូ ។

នៅក្នុងអំឡុងពេលនៃការអនុវត្តផែនការគោលនេះ នឹងមានការរៀបចំផែនការពង្រីកបច្ចេកវិទ្យាបច្ចុប្បន្នទៅកាន់តំបន់ដាច់ស្រយាល និងការអប់រំនៅកម្រិតទាបៗបន្ថែមទៀត ហើយនឹងមានការសិក្សាពីការប្រើប្រាស់បច្ចេកវិទ្យាសមស្របផ្សេងទៀតសម្រាប់ប្រទេសកម្ពុជា (ដូចជាទូរសព្ទចល័តជាដើម) ។

### ការគ្រប់គ្រងកម្មវិធី បពស នៅក្រសួង អយក

សមាសធាតុចម្បងមួយនៃផែនការគោលនេះ គឺធានាថាការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ មានធនធានមនុស្ស និងសម្ភារគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងតាមដានកម្មវិធី បពស ។ ដើម្បីសម្រេចគោលបំណងនេះ បីឆ្នាំដំបូងនៃការអនុវត្តផែនការគោលនេះ និស្សិតឆ្នើមចំនួន ៤ រូប ក្នុងមួយឆ្នាំ ដែលបានបញ្ចប់ការសិក្សា បពស ពីវិទ្យាស្ថានជាតិអប់រំ នឹងត្រូវចាត់ឲ្យចូលបម្រើការងារនៅការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ ដើម្បីបំពេញការងារបណ្តុះបណ្តាលចម្បងៗ និងការងារគ្រប់គ្រង ដោយក្រសួងមានគម្រោងបង្កើនចំនួនបុគ្គលិកការិយាល័យនេះជារៀងរាល់ឆ្នាំ ។

## ៦.៥. សមភាព និងសីលធម៌

សង្គមនីមួយៗតែងតែមានវិសមភាពដែលមិនអាចបំបាត់បានទាំងស្រុងដោយប្រព័ន្ធអប់រំ ប៉ុន្តែផែនការគោលនេះ និងផែនការផ្សេងទៀតរបស់ក្រសួងព្យាយាមធានាថា សកម្មភាពរបស់ខ្លួននឹងជួយកាត់បន្ថយវិសមភាព ហើយចៀសវាងមិនឲ្យមានការកើនឡើង។ ការតាមដាន និងកែតម្រូវជាវិធីសាស្ត្រចម្បងដែលផែនការនេះប្រើក្នុងការតាមដាន និងលុបបំបាត់ផលប៉ះពាល់អវិជ្ជមានដែលអាចនឹងកើតមាន ។

ខណៈដែលផែនការគោលនេះ មិនអាចសម្រេចពីការចូលសិក្សា បពស របស់សិស្ស ឬរបស់លោកគ្រូអ្នកគ្រូ (ចំនួនសិស្ស និងគ្រូដែលអាចចូលសិក្សាមានចំនួនកំណត់) ផែនការគោលនេះ នឹងធានាថា (ក) គ្មានឧបសគ្គពិសេសក្នុងការទទួលបានការបណ្តុះបណ្តាល បពស (ខ) មានការតាមដានលទ្ធផលដើម្បីធានាថាគ្មានការរើសអើង (គ) មានតាមដានលុបបំបាត់គម្លាតដែលនឹងអាចនាំឲ្យមានវិសមភាពកាន់តែខ្លាំងឡើងរវាងអ្នកមាន និងអ្នកក្រ អ្នកជនបទ និងអ្នកទីក្រុង បុរស និងស្ត្រី ។ ការប្រយុទ្ធប្រឆាំងនឹងវិសមភាពយេនឌ័រ ជាចំណុចសំខាន់ជាពិសេស ។ ក្រសួង ត្រូវចាត់វិធានការដែលអំណោយផលដល់ការធានាសមភាពរវាងបុរស និងស្ត្រីនៅក្នុងការបណ្តុះបណ្តាលគ្រូពីជំនាញ បពស

និងត្រូវចាត់វិធានការដែលមិនត្រឹមតែធានាថាសម្ភារឧបទេស និងកម្មវិធីសិក្សាគ្មានការរើសអើងយេនឌ័រ ប៉ុន្តែថែមទាំងមានបញ្ចូលនូវខ្លឹមសារសមភាពយេនឌ័រផង ។

## សីលធម៌

ប្រព័ន្ធអប់រំ ត្រូវធានាថា ឥរិយាបថដែលបង្រៀនមានភាពត្រឹមត្រូវ និងមានសីលធម៌ ទោះដោយជាក់ច្បាស់ក្តី និងមិនជាក់ច្បាស់ក្តី ។ ការគោរពច្បាប់ និងទំនៀមទម្លាប់ ត្រូវតែឆ្លុះបញ្ចាំងនៅក្នុងសម្ភារឧបទេសទាំងអស់ ។

ផែនការគោលនេះត្រូវបានអភិវឌ្ឍក្រោមការត្រួតពិនិត្យពី**គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ**
នៃក្រសួងអប់រំ យុវជន និងកីឡា

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ឹម សិទ្ធី** | រដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- លោកជំទាវ **តឿន សភុណ្ណា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤- ឯកឧត្តម **ហាក់ សឺងលី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥- ឯកឧត្តម **អ៊ើ ណៃលាង** | អគ្គនាយកអប់រំ | សមាជិក |
| ៦- ឯកឧត្តម **អ៊ិន ថេរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម **ម៉ក់ ថាវិន** | អគ្គនាយកឧត្តមសិក្សា | សមាជិក |
| ៨- លោក **ឱម សិទ្ធី** | ប្រធាននាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន | សមាជិកអចិន្ត្រៃយ៍ |
| ៩- លោក **លាង សេងហាក់** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | សមាជិក |
| ១០- លោក **ថោង បូរ៉ាន់** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១១- លោក **សំ សេរីរតន៍** | ប្រធាននាយកដ្ឋានផែនការ | សមាជិក |
| ១២- លោក **លី សទ្ធិ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ១៣- លោក **ច្រឹង លឹមស្រ៊ី** | ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | សមាជិក |
| ១៤- លោក **អេង គឹមលី** | ប្រធាននាយកដ្ឋានស្រាវជ្រាវគរុកោសល្យ | សមាជិក |
| ១៥- លោក **គុង ហានស៊ីន** | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | សមាជិក |
| ១៦- លោក **រ័ត្ន សុខា** | ប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ១៧- លោក **ច័ន្ទ រ័ត្ន** | ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៨- លោក **អ៊ឹម ឆាយហៀង** | អនុប្រធាននាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន | សមាជិក |
| ១៩- លោក **សុភ ថា** | ប្រធានការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ( នា. ពអស ) | លេខាធិការ |

## ដំណើរការអភិវឌ្ឍផែនការគោល

អំឡុងពេលធ្វើសេចក្តីព្រាងដោយក្រុមការងារស្នូលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងបុគ្គលិករបស់ដៃគូអភិវឌ្ឍន៍ ផែនការគោលបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំនេះ បានអភិវឌ្ឍជាបន្តបន្ទាប់ដោយមានការពិគ្រោះយោបល់យ៉ាងហ្មត់ចត់ ដោយមានការចូលរួមពីនាយកដ្ឋានពាក់ព័ន្ធទាំងអស់របស់ក្រសួងតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់បីលើក ដែលបានធ្វើការពិភាក្សាលើសេចក្តីព្រាងផ្សេងៗ គ្នានៃផែនការមេនេះ ។ ដំណើរការនេះធ្វើឡើងដោយមានការពិគ្រោះយោបល់ជាសាធារណៈជាមួយក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ។

## ដំណើរការអភិវឌ្ឍស្ថិតក្រោមការសម្របសម្រួលដោយ ៖

លោក **ឱម សិទ្ធី** ប្រធាននាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាននៃក្រសួងអប់រំ យុវជន និងកីឡា

ដោយមានការគាំទ្រផ្នែកបច្ចេកទេសពី ៖

លោក **សុភ ថា** ប្រធានការិយាល័យ បច្ចេកវិទ្យាព័ត៌មានអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា
កញ្ញា **ហេង ចាន់ថេង** វិទ្យាស្ថានបើកទូលាយ
លោក **ខេង ពិសិដ្ឋ** វិទ្យាស្ថានបើកទូលាយ

លោក **ហាបៀរ សូឡា** វិទ្យាស្ថានបើកទូលាយ
លោក **Benjamin Vergel de Dios** - UNESCO បាងកក
លោកបណ្ឌិត **Fengchun Miao** - UNESCO បាងកក
លោកស្រី **ស៊ុន ឡេ** - UNESCO ភ្នំពេញ

ឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ដំណើរការអភិវឌ្ឍពី ៖

វិទ្យាស្ថានបើកទូលាយ
Open Institute

UNESCO
United Nations
Educational, Scientific and
Cultural Organization

MINISTERIO
DE ASUNTOS EXTERIORES
Y DE COOPERACIÓN

aecid

inwent
Capacity Building International, Germany